ក្រសួងមហាផ្ទៃ

## សៀវភៅណែនាំស្តីពី



# ការអនុវត្តសកម្មភាព
# សេវាសង្គមឃុំ សង្កាត់

ខែឧសភា ឆ្នាំ២០១៨

# មាតិកា

សេចក្តីផ្តើម...................................................................................................................១

**ការវិភាគ និងការចាត់អាទិភាពនៃបញ្ហា**

ជំពូកទី១
១.១. បញ្ហាសេវាសង្គម.......................................................................................... ៤
១.១.១. សូចនាករទាក់ទងបញ្ហាសុខភាពមាតា ទារក និងអាហារូបត្ថម្ភ.................................... ៤
១.១.២. សូចនាករទាក់ទងបញ្ហាទឹកស្អាត និងអនាម័យ........................................................ ៤
១.១.៣. សូចនាករទាក់ទងបញ្ហាកិច្ចការពារកុមារ................................................................. ៤
១.១.៤. សូចនាករទាក់ទងបញ្ហាការអប់រំកុមារតូច.............................................................. ៤
១.១.៥. សូចនាករទាក់ទងបញ្ហាភាពងាយរងគ្រោះ.............................................................. ៥
១.២. ការកំណត់បញ្ហាតាមរយៈផែនទីសេវាសង្គមភូមិ.................................................................. ៥
១.៣. ការរៀបចំតារាងវិភាគបញ្ហា តម្រូវការ និងដំណោះស្រាយ.................................................. ១៣

ជំពូកទី២

**ការរៀបចំផែនការសកម្មភាព និងថវិកា**

២.១. ការរៀបចំផែនការសកម្មភាព និងថវិកាសេវាសង្គមប្រចាំឆ្នាំ............................................... ១៩
២.២. ការរៀបចំផែនការសកម្មភាព និងថវិកាសេវាសង្គមប្រចាំត្រីមាស........................................១៩

ជំពូកទី៣

**ការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃសកម្មភាពសេវាសង្គម**

៣.១.កិច្ចការសំខាន់ដែលត្រូវធ្វើនៅក្នុងការអនុវត្តសកម្មភាពសេវាសង្គម........................................ ៣០
៣.១.១. ការប្រើប្រាស់ខ្ទង់ថវិកា................................................................................... ៣០
៣.១.២. ការរៀបចំអនុវត្តសកម្មភាពសេវាសង្គម................................................................. ៣០
៣.១.៣. ការរៀបចំសំណើសុំថវិកា................................................................................ ៣៥
៣.១.៤. ការទូទាត់ថវិកា................................................................................................ ៣៥
៣.២. ការតាមដានត្រួតពិនិត្យសកម្មភាពសេវាសង្គម............................................................... ៣៥
៣.៣. ការតាមដានត្រួតពិនិត្យថវិកាសេវាសង្គម.................................................................... ៣៦

ជំពូកទី៤

## របាយការណ៍លទ្ធផល នៃការអនុវត្តសកម្មភាព និងថវិកាសេវាសង្គម

ជំពូកទី៥

## យន្តការគាំទ្រក្នុងការអនុវត្តសកម្មភាពសេវាសង្គម


៥.១. រដ្ឋបាលរាជធានី ខេត្ត........................................................................................... ៤៥
៥.២. រដ្ឋបាលក្រុង ស្រុក ខណ្ឌ.......................................................................................៤៦
៥.៣. មន្ទីរសុខាភិបាល................................................................................................ ៤៦
៥.៤. មន្ទីរអប់រំយុវជន និងកីឡា.....................................................................................៤៧
៥.៥. មន្ទីរអភិវឌ្ឍន៍ជនបទ...............................................................................................៤៧
៥.៦. មន្ទីរកិច្ចការនារី......................................................................................................៤៨
៥.៧. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា........................................................ ៤៨
៥.៨. អង្គការសង្គមស៊ីវិល................................................................................................. ៤៩
៥.៩. ប្រជាពលរដ្ឋ............................................................................................................៤៩
ឧបសម្ព័ន្ធ............................................................................................................................ ៥០
- សេចក្តីណែនាំលេខ ៥៦៦ អ.រតន. ស្តីពីការកំណត់មាតិកាថវិកា និង លិខិតយុត្តិការចំណាយសម្រាប់ទូទាត់សេវាសង្គមនៅរដ្ឋបាល ឃុំ សង្កាត់ ............................................................៥១
- អត្ថន័យនៃសូចនាករទាំង១៤.........................................................................................៦១
-ឯកសារជំនួយស្មារតី ស្តីពីប្រភេទនៃអំពើហិង្សាលើកុមារ..........................................................៦៣
- ឯកសារជំនួយស្មារតី ស្តីពីការធ្វើឲ្យប្រសើរឡើងនូវការថែទាំកុមារនៅតាមគ្រួសារ និងការធ្វើសមាហរណកម្មកុមារ ពីមណ្ឌលថែទាំកុមារ ទៅកាន់គ្រួសារប្រកបដោយសុវត្ថិភាពសម្រាប់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់(គ.ក.ន.ក)...................................៦៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ [illegible]

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហាឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងប្រកាសលេខ៤២៧៥ ប្រ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

- យោងសេចក្តីណែនាំលេខ០៨២ សណន/ក.ជ.ក.ក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស។

**សម្រេច**

**ប្រការ ១.-**

ដាក់ឱ្យប្រើប្រាស់នូវសៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់ សម្រាប់ប្រើប្រាស់ក្នុងការរៀបចំ និងអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់។

**ប្រការ ២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ បុគ្គលិកឃុំ សង្កាត់ មន្ត្រីរាជការដែលមានភារកិច្ចគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានា ត្រូវអនុវត្តតាមគោលការណ៍ បែបបទ និងនីតិវិធីនានាដែលបានកំណត់នៅក្នុងសៀវភៅណែនាំនេះ ក្នុងការរៀបចំ និងអនុវត្តសកម្មភាពសេវាសង្គមទាំងឡាយរបស់រដ្ឋបាលឃុំ សង្កាត់។

**ប្រការ ៣.-**

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ៖**

- ក្រសួង ស្ថាប័នជាសមាជិក គ.ជ.អ.ប
- លេខាធិការដ្ឋាន គ.ជ.អ.ប
- អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រដ្ឋបាលឃុំ សង្កាត់
- ឯកសារ-កាលប្បវត្តិ

# សេចក្ដីផ្ដើម

ចាប់តាំងពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០០២ ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ បានរៀបចំឯកសារបច្ចេកទេសនានាពាក់ព័ន្ធនឹងការងារសេវាសង្គម ដើម្បីអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់។ ឯកសារបច្ចេកទេសទាំងនោះមិនទាន់មានលក្ខណៈប្រមូលផ្ដុំនៅឡើយ ដែលជាហេតុធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ជួបការលំបាកក្នុងការអនុវត្តសកម្មភាពសេវាសង្គម។ ដូច្នេះដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងលើ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប បានសហការរៀបចំសៀវភៅណែនាំស្ដីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់ ឱ្យមានលក្ខណៈសាមញ្ញ និងងាយស្រួលប្រើប្រាស់។

សៀវភៅណែនាំស្ដីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់រៀបចំឡើងក្នុងគោលបំណងសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំនិងការអនុវត្តសកម្មភាពសេវាសង្គមប្រកបដោយប្រសិទ្ធភាពតម្លាភាពនិងសមធម៌។

សៀវភៅណែនាំនេះបរិយាយអំពីដំណាក់កាលនៃការរៀបចំ និងការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់ដោយចែកចេញជា៥ជំពូក។

**ជំពូកទី១**

### ការវិភាគ និងការចាត់អាទិភាពនៃបញ្ហា

ជំពូកនេះ បរិយាយអំពីដំណើរការនៃការរៀបចំផែនទីសេវាសង្គមភូមិ ដើម្បីកំណត់តម្រូវការអាទិភាពសម្រាប់ដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**ជំពូកទី២**

### ការរៀបចំផែនការសកម្មភាព និងថវិកា

ជំពូកនេះបរិយាយអំពីការរៀបចំផែនការសកម្មភាព និងថវិកាសេវាសង្គមដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព។

**ជំពូកទី៣**

### ការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃសកម្មភាពសេវាសង្គម

ជំពូកនេះបរិយាយអំពីការអនុវត្តសកម្មភាព ការប្រើប្រាស់ថវិកា ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើសកម្មភាព និងថវិកាសេវាសង្គមដែលបានអនុម័ត។

**ជំពូកទី៤**

### របាយការណ៍លទ្ធផលនៃការអនុវត្តសកម្មភាព និងថវិកាសេវាសង្គម

ជំពូកនេះបរិយាយអំពីការរៀបចំរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តសកម្មភាព និងថវិកាសេវាសង្គម។

**ជំពូកទី៥**

### យន្តការគាំទ្រក្នុងការអនុវត្តសកម្មភាពសេវាសង្គម

ជំពូកនេះបរិយាយអំពីតួនាទី ភារកិច្ចរបស់អ្នកពាក់ព័ន្ធក្នុងការគាំទ្រដល់ដំណើរការនៃការរៀបចំ និងការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់។

# ជំពូកទី១

# ការវិភាគ និងការចាត់អាទិភាពនៃបញ្ហា

ជំពូកនេះ៖ បរិយាយអំពីដំណើរការនៃការរៀបចំផែនទីសេវាសង្គមភូមិដើម្បីកំណត់តម្រូវការអាទិភាពសម្រាប់ដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។



ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំគូសផែនទីសេវាសង្គមភូមិ
ភូមិចាអ៊ុងចាន់ ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគីរី
© UNICEF Cambodia /2017/Antoine Raab

## ១.១. បញ្ហាសេវាសង្គម

បញ្ហាសេវាសង្គមមួយចំនួននៅឃុំ សង្កាត់មានដូចជា សុខភាពមាតា ទារក និងអាហារូបត្ថម្ភ អនាម័យ និងទឹកស្អាត កិច្ចការពារកុមារ ការអប់រំកុមារតូច និងភាពងាយរងគ្រោះជាដើម។ បញ្ហាទាំងនោះសុទ្ធសឹងតែជាអាទិភាពតម្រូវឱ្យស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) បង្កើនការយកចិត្តទុកដាក់ក្នុងការផ្តល់សេវាសង្គមឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងសមធម៌។

ខាងក្រោមនេះ គឺជាសូចនាករសេវាសង្គមដែលត្រូវយកចិត្តទុកដាក់៖



### ១.១.១. សូចនាករទាក់ទងបញ្ហាសុខភាពមាតា ទារក និងអាហារូបត្ថម្ភ

០១. ខ្នងផ្ទះមានស្ត្រីមានផ្ទៃពោះមិនបានទៅពិនិត្យផ្ទៃពោះមុនពេលសម្រាល
០២. ខ្នងផ្ទះមានស្ត្រីមានផ្ទៃពោះមិនបានសម្រាលកូននៅមូលដ្ឋានសុខាភិបាល
០៣. ខ្នងផ្ទះមានកុមារអាយុ១២-២៣ខែ ដែលមិនបានចាក់ថ្នាំបង្ការគ្រប់
០៤. ខ្នងផ្ទះមានកុមារស្គមស្គាំងនៅអាយុក្រោម៥ឆ្នាំ



### ១.១.២. សូចនាករទាក់ទងបញ្ហាទឹកស្អាត និងអនាម័យ

០៥. ខ្នងផ្ទះគ្មានបង្គន់អនាម័យប្រើប្រាស់
០៦. ខ្នងផ្ទះមិនបរិភោគទឹកមានសុវត្ថិភាព



### ១.១.៣. សូចនាករទាក់ទងបញ្ហាកិច្ចការពារកុមារ

០៧. ខ្នងផ្ទះដែលមានកុមារធ្លាប់ទទួលរងអំពើហិង្សា
០៨. ខ្នងផ្ទះមានកុមារងាយរងគ្រោះចំពោះការបែកចេញពីគ្រួសារ
០៩. ខ្នងផ្ទះមានកុមារវិលត្រលប់មកពីមណ្ឌលកុមារកំព្រារស់នៅជាមួយ
១០. ខ្នងផ្ទះមានសមាជិកគ្រួសារដែលគ្មានសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត



### ១.១.៤. សូចនាករទាក់ទងបញ្ហាការអប់រំកុមារតូច

១១. ខ្នងផ្ទះមានកុមារអាយុ៣-៥ឆ្នាំមិនបានទទួលការអប់រំគ្រប់ទម្រង់នៃការអប់រំកុមារតូច
១២. ខ្នងផ្ទះមានកុមាររៀននៅបឋមសិក្សា ហើយអាណាព្យាបាលមិនដែលបានជួបជាមួយតំណាងសាលា ឬគ្រូ

### ១.១.៥. សូចនាករទាក់ទងបញ្ហាភាពងាយរងគ្រោះ

១៣. ខ្នងផ្ទះមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ(ប័ណ្ណក្រីក្រ) មានសុពលភាព
១៤. ខ្នងផ្ទះមានសមាជិកមានពិការភាព

## ១.២. ការកំណត់បញ្ហាតាមរយៈផែនទីសេវាសង្គមភូមិ

ផែនទីសេវាសង្គម គឺជាឧបករណ៍មួយសម្រាប់សហគមន៍ចូលរួមកំណត់ និងគូសសម្គាល់នៅលើផែនទីភូមិនូវខ្នងផ្ទះ ធនធាន និងសេវាកម្មនានា ព្រមទាំងកំណត់រកគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះដើម្បីងាយស្រួលក្នុងការផ្តល់សេវាសង្គមប្រកបដោយតម្លាភាព សមធម៌ និងមានការចូលរួមពីភាគីពាក់ព័ន្ធ។

មុននឹងរៀបចំផែនទីសេវាសង្គមភូមិ មេឃុំ ចៅសង្កាត់ ត្រូវប្រមូលទិន្នន័យមួយចំនួនជាមូលដ្ឋានទាក់ទងនឹងផ្នែកសុខភាពមាតា ទារក និងអាហារូបត្ថម្ភពីមណ្ឌលសុខភាព និងទិន្នន័យផ្សេងៗទៀតពីប៉ុស្តិ៍នគរបាលរដ្ឋបាល ព្រមទាំងប្រភពទិន្នន័យនានានៅក្នុងភូមិ ឬ ឃុំ សង្កាត់។ ទិន្នន័យទាំងនេះ ត្រូវស្រង់ចូលក្នុងទម្រង់១ ដូចមានជាឧទាហរណ៍ខាងក្រោម ដើម្បីប្រគល់ឱ្យទៅមេភូមិសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំផែនទីសេវាសង្គមភូមិ។

### ទម្រង់១៖

**ទិន្នន័យពីមណ្ឌលសុខភាព និងប្រភពផ្សេងៗ**
**រដ្ឋបាលឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ........រាជធានី ខេត្ត ..................**

| ល.រ | ឈ្មោះភូមិ | មណ្ឌលសុខភាព | | | | ប៉ុស្តិ៍នគរបាល និងប្រភពផ្សេងៗ | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ស្ត្រីមានផ្ទៃពោះមិនបានទៅពិនិត្យផ្ទៃពោះមុនពេលសម្រាល | ស្ត្រីមានផ្ទៃពោះមិនបានសម្រាលកូននៅមូលដ្ឋានសុខាភិបាល | កុមារអាយុ ១២-២៣ខែ ដែលមិនបានចាក់ថ្នាំបង្ការគ្រប់ | កុមារស្គមស្គាំងនៅអាយុក្រោម ៥ឆ្នាំ | ពលកម្មកុមារ | កុមារចំណាកស្រុក | ការជួញដូរកុមារ | ការរំលោភបំពានរាងកាយនិងការរំលោភបំពានផ្លូវភេទ | បញ្ហាផ្សេងៗ --------- | |
| ១ | ចាអ៊ុងកៅ | | | | | | | | | | |
| ២ | ធ្លួយអំពិល | | | | | | | | | | |
| ៣ | ធ្លួយទុំ | | | | | | | | | | |
| ៤ | ចាអ៊ុងកេត | | | | | | | | | | |
| ៥ | ចាអ៊ុងចាន់ | | | | | | | | | | |
| សរុប | | | | | | | | | | | |

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........
អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

ផែនទីសេវាសង្គមត្រូវបង្កើតឡើងតាមជំហានបន្តបន្ទាប់ ដូចខាងក្រោម៖

## ក). ជំហាន១៖ ការរៀបចំសេចក្តីព្រាងតារាង និងផែនទីសេវាសង្គមភូមិ

សកម្មភាពសំខាន់ៗនៅក្នុងជំហាន១ រួមមាន៖

- មេឃុំ ចៅសង្កាត់ ត្រូវប្រជុំជាមួយមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ដើម្បីណែនាំអំពីគោលបំណង ជំហាននៃការរៀបចំផែនទីសេវាសង្គមភូមិ ការកំណត់កាលបរិច្ឆេទ ទីកន្លែង ចំនួនប្រជាពលរដ្ឋចូលរួម និងបែងចែកតួនាទីអ្នកសម្របសម្រួលដំណើរការគូសផែនទីនៅតាមភូមិនីមួយៗ ព្រមទាំងផ្តល់ទិន្នន័យពីមណ្ឌលសុខភាព ប៉ុស្តិ៍នគរបាល និងប្រភពផ្សេងៗទៀត (ទម្រង់១) ឱ្យទៅមេភូមិ
- មេភូមិនីមួយៗរៀបចំសេចក្តីព្រាងផែនទីសេវាសង្គម (ដូចមានជាឧទាហរណ៍ខាងក្រោមស្តីពីគំរូសេចក្តីព្រាងផែនទីសេវាសង្គមភូមិ) ដោយមានបញ្ចូលព័ត៌មានសំខាន់ៗដូចខាងក្រោម៖
  - ឈ្មោះភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត
  - កាលបរិច្ឆេទ
  - ផ្លូវថ្នល់ ស្រះ អណ្តូងទឹក និងទីតាំងផ្តល់សេវាសង្គមសំខាន់ៗ ដូចជាមណ្ឌលសុខភាព សាលារៀន និងសាលាឃុំ សង្កាត់ ។ល។
  - ខ្នងផ្ទះ និងលេខកូដខ្នងផ្ទះ
  - និមិត្តសញ្ញាប្រាប់ទិសផែនទី ដោយប្រើខាងលើជាទិសខាងជើង
  - និមិត្តសញ្ញាកំណត់ចំណាំសំខាន់ៗដែលមាននៅលើផែនទី
- មេភូមិត្រូវប្រើប្រាស់ទម្រង់២ ដើម្បីបំពេញលេខកូដខ្នងផ្ទះ និងឈ្មោះមេខ្នងផ្ទះសម្រាប់យកទៅប្រជុំក្នុងជំហាន២ ។

# ទម្រង់២៖

## តារាងទិន្នន័យសេវាសង្គមភូមិ
## ភូមិចាអ៊ុងកៅ ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគិរី

| លេខកូដខ្នងផ្ទះ (១) | ឈ្មោះមេគ្រួសារតាមខ្នងផ្ទះ (២) | សូចនាករសេវាសង្គម (៣) (គូសសញ្ញា √ ចំពោះខ្នងផ្ទះដែលត្រូវនឹងកត្តាចង្អុលបង្ហាញបញ្ហានីមួយៗ) | | | | | | | | | | | | | | សរុប (៤) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ០១ | ០២ | ០៣ | ០៤ | ០៥ | ០៦ | ០៧ | ០៨ | ០៩ | ១០ | ១១ | ១២ | ១៣ | ១៤ | |
| ០០១ | សំ ញៀន | | | | | | | | | | | | | | | |
| ០០២ | អ៊ុក ផា | | | | | | | | | | | | | | | |
| ០០៣ | ហេង សំរិត | | | | | | | | | | | | | | | |
| ០០៤ | ហ៊ាង ចំរើន | | | | | | | | | | | | | | | |
| ០០៥ | កុយ សុភ័ក្រ្ត | | | | | | | | | | | | | | | |
| ..... | ................ | | | | | | | | | | | | | | | |
| ..... | ................ | | | | | | | | | | | | | | | |
| ១១១ | គា កុម្ភៈ | | | | | | | | | | | | | | | |
| | សរុប | | | | | | | | | | | | | | | |

- បើសូចនាករបញ្ហាណាដែលមានខ្នងផ្ទះសរុបច្រើនជាងគេ (មើលក្នុងជួរផ្តេកក្រោមគេបំផុត-សរុបខ្នងផ្ទះតាមសូចនាករបញ្ហានីមួយៗ) មានន័យថាសូចនាករនោះ គឺជាបញ្ហាអាទិភាពខ្លាំងជាងគេ ដែលក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិត្រូវពិចារណាក្នុងការដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។
- បើខ្នងផ្ទះណាដែលមានចំនួនសរុបសូចនាករបញ្ហាច្រើនជាងគេ (មើលក្នុងកូឡោនទី៤) ឬមានតម្រូវការជំនួយបន្ទាន់ មានន័យថាខ្នងផ្ទះនោះមានភាពងាយរងគ្រោះដែលក្រុមប្រឹក្សាឃុំសង្កាត់ និងមេភូមិត្រូវពិចារណាក្នុងការផ្តល់អាទិភាពខ្ពស់ជាងគេសម្រាប់កំណត់ជាក្រុមគោលដៅក្នុងការទទួលសេវាសង្គម។
- ភូមិអាចបន្ថែមសូចនាករថ្មីបានតាមការចាំបាច់ និងតម្រូវការរបស់ដៃគូអភិវឌ្ឍន៍នានា។

ថ្ងៃ....... ខែ....... ឆ្នាំ....... .......ស័ក ព.ស.២៥.....
ភូមិ.............ថ្ងៃទី.......... ខែ........ ឆ្នាំ..........
មេភូមិ




## ខ). ជំហាន២៖ ការរៀបចំផែនទីសេវាសង្គមភូមិ

ផែនទីសេវាសង្គមនៅតាមភូមិនីមួយៗរៀបចំឡើងក្រោមការដឹកនាំ និងការសម្របសម្រួលពីមេភូមិ ដោយមានការចូលរួមពីអនុប្រធានភូមិ សមាជិកភូមិ និងប្រជាពលរដ្ឋជាមេខ្ទង់ផ្ទះភាគច្រើនដែលមកពីគ្រប់ក្រុមប្រជាពលរដ្ឋក្នុងភូមិ ដូចជា តំណាងជនពិការ យុវជន ស្ត្រី និងជនជាតិដើមភាគតិច។ល។ ព្រមទាំងមានការគាំទ្រពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងឬមន្ត្រីការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់។ ការរៀបចំផែនទីសេវាសង្គមភូមិ មេភូមិត្រូវ៖

- បង្ហាញអំពីគោលបំណងនៃការរៀបចំផែនទីសេវាសង្គម
- សួរផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃសេចក្ដីព្រាងផែនទីសេវាសង្គមដែលបានរៀបចំនៅក្នុងជំហាន១ និងកែតម្រូវក្នុងករណីមិនទាន់មានភាពត្រឹមត្រូវ
- ប្រើប្រាស់សំណួរគន្លឹះដូចខាងក្រោម ដើម្បីជាជំនួយក្នុងការកំណត់រកខ្ទង់ផ្ទះដែលមិនបានទទួលសេវាសង្គម (គ្រប់សំណួរទាំងអស់ សូមឱ្យប្រជាពលរដ្ឋលើកដៃ លើកលែងសំណួរក្នុងសូចនាករទី៨)។

# បញ្ជីសំណួរគន្លឹះសម្រាប់កំណត់បញ្ហាសេវាសង្គម

| ល.រ | សូចនាករ | សំណួរគន្លឹះ |
|---|---|---|
| **បញ្ហាសុខភាពមាតា ទារក និងអាហារូបត្ថម្ភ** | | |
| ០១ | ខ្នងផ្ទះមានស្ត្រីមានផ្ទៃពោះមិនបានទៅពិនិត្យផ្ទៃពោះមុនពេលសម្រាល | ▪ តើខ្នងផ្ទះណាខ្លះដែលមានស្ត្រីមានផ្ទៃពោះមិនបានទៅពិនិត្យផ្ទៃពោះមុនសម្រាលក្នុង១២ខែចុងក្រោយ?<br>▪ តើមានដឹងថាខ្នងផ្ទះណាខ្លះទៀតដែលមានស្ត្រីមានផ្ទៃពោះមិនបានទៅពិនិត្យផ្ទៃពោះមុនសម្រាលក្នុង១២ខែចុងក្រោយ? |
| ០២ | ខ្នងផ្ទះមានស្ត្រីមានផ្ទៃពោះមិនបានសម្រាលកូននៅមូលដ្ឋានសុខាភិបាល | ▪ តើខ្នងផ្ទះណាខ្លះដែលមានស្ត្រីមានផ្ទៃពោះមិនបានសម្រាលកូននៅមូលដ្ឋានសុខាភិបាលក្នុង១២ខែចុងក្រោយ?<br>▪ តើមានដឹងថាខ្នងផ្ទះណាខ្លះទៀតដែលមានស្ត្រីមានផ្ទៃពោះមិនបានសម្រាលកូននៅមូលដ្ឋានសុខាភិបាលក្នុង១២ខែចុងក្រោយ? |
| ០៣ | ខ្នងផ្ទះមានកុមារអាយុ១២-២៣ខែដែលមិនបានចាក់ថ្នាំបង្ការគ្រប់ | ▪ តើខ្នងផ្ទះណាខ្លះដែលមានកុមារអាយុ១២-២៣ខែដែលមិនបានចាក់ថ្នាំបង្ការគ្រប់?<br>▪ តើមានដឹងថាខ្នងផ្ទះណាខ្លះទៀតដែលមានកុមារអាយុ១២-២៣ខែដែលមិនបានចាក់ថ្នាំបង្ការគ្រប់? |
| ០៤ | ខ្នងផ្ទះមានកុមារស្គមស្គាំងនៅអាយុក្រោម៥ឆ្នាំ | ▪ តើខ្នងផ្ទះណាខ្លះមានកុមារស្គមស្គាំងនៅអាយុក្រោម៥ឆ្នាំ?<br>▪ តើមានដឹងថាខ្នងផ្ទះណាខ្លះទៀតដែលមានកុមារស្គមស្គាំងនៅអាយុក្រោម៥ឆ្នាំ? |
| **បញ្ហាទឹកស្អាត និងអនាម័យ** | | |
| ០៥ | ខ្នងផ្ទះគ្មានបង្គន់អនាម័យប្រើប្រាស់ | ▪ តើខ្នងផ្ទះណាខ្លះដែលគ្មានបង្គន់អនាម័យប្រើប្រាស់?<br>▪ តើមានដឹងថាខ្នងផ្ទះណាខ្លះទៀត ដែលគ្មានបង្គន់អនាម័យប្រើប្រាស់? |
| ០៦ | ខ្នងផ្ទះមិនបរិភោគទឹកមានសុវត្ថិភាព | ▪ តើខ្នងផ្ទះណាខ្លះដែលមិនបរិភោគទឹកមានសុវត្ថិភាព?<br>▪ តើមានដឹងថាខ្នងផ្ទះណាខ្លះទៀត ដែលខ្នងផ្ទះមិនបរិភោគទឹកមានសុវត្ថិភាព? |
| **បញ្ហាកិច្ចការពារកុមារ** | | |
| ០៧ | ខ្នងផ្ទះដែលមានកុមារធ្លាប់ទទួលរងអំពើហិង្សា | ▪ តើខ្នងផ្ទះណាខ្លះដែលមានកុមារធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ និងផ្លូវចិត្តក្នុង១២ខែចុងក្រោយ?<br>▪ តើខ្នងផ្ទះណាខ្លះទៀតដែលមានកុមារធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ និងផ្លូវចិត្តក្នុង១២ខែចុងក្រោយ? |
| ០៨ | ខ្នងផ្ទះមានកុមារងាយរងគ្រោះចំពោះការបែកចេញពីគ្រួសារ | (សូមសរសេរចម្លើយជាលាយលក្ខណ៍អក្សរជំនួសដោយការលើកដៃ)<br>▪ តើខ្នងផ្ទះណាខ្លះដែលមានកុមារងាយរងគ្រោះចំពោះការបែកចេញពីគ្រួសារ?<br>▪ តើមានខ្នងផ្ទះណាខ្លះទៀតដែលមានកុមារងាយរងគ្រោះចំពោះការបែកចេញពីគ្រួសារ? |

| ល.រ | សូចនាករ | សំណួរគន្លឹះ |
|---|---|---|
| ០៩ | ខ្នងផ្ទះមានកុមារវិលត្រលប់មកពីមណ្ឌលកុមារកំព្រារស់នៅជាមួយ | ▪ តើខ្នងផ្ទះណាខ្លះដែលមានកុមារវិលត្រលប់មកពីមណ្ឌលកុមារកំព្រារស់នៅជាមួយ?<br>▪ តើមានខ្នងផ្ទះណាខ្លះទៀតដែលមានកុមារវិលត្រលប់មកពីមណ្ឌលកុមារកំព្រារស់នៅជាមួយ? |
| ១០ | ខ្នងផ្ទះមានសមាជិកគ្រួសារដែលគ្មានសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត | ▪ តើខ្នងផ្ទះណាខ្លះដែលមានសមាជិកគ្រួសារគ្មានសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត?<br>▪ តើមានខ្នងផ្ទះណាខ្លះទៀត ដែលមានសមាជិកគ្មានសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត? |
| | **បញ្ហាការអប់រំកុមារតូច** | |
| ១១ | ខ្នងផ្ទះមានកុមារអាយុ៣-៥ឆ្នាំមិនបានទទួលការអប់រំគ្រប់ទម្រង់នៃការអប់រំកុមារតូច | ▪ តើខ្នងផ្ទះណាខ្លះ ដែលមានកុមារអាយុ៣-៥ឆ្នាំ មិនបានទទួលការអប់រំគ្រប់ទម្រង់នៃការអប់រំកុមារតូច?<br>▪ តើខ្នងផ្ទះណាខ្លះទៀត ដែលមានកុមារអាយុ៣-៥ឆ្នាំ មិនបានទទួលការអប់រំគ្រប់ទម្រង់នៃការអប់រំកុមារតូច? |
| ១២ | ខ្នងផ្ទះមានកុមាររៀននៅបឋមសិក្សាហើយអាណាព្យាបាលមិនដែលបានជួបជាមួយតំណាងសាលា ឬគ្រូ | ▪ តើខ្នងផ្ទះណាខ្លះមានកុមាររៀននៅបឋមសិក្សា ហើយអាណាព្យាបាលមិនដែលបានជួបជាមួយតំណាងសាលា ឬគ្រូ?<br>▪ តើខ្នងផ្ទះណាខ្លះមានកុមាររៀននៅបឋមសិក្សា ហើយអាណាព្យាបាលមិនដែលបានជួបជាមួយតំណាងសាលា ឬគ្រូ? |
| | **បញ្ហាភាពងាយរងគ្រោះ** | |
| ១៣ | ខ្នងផ្ទះមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ(ប័ណ្ណក្រីក្រ)មានសុពលភាព | ▪ តើខ្នងផ្ទះណាខ្លះមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ(ប័ណ្ណក្រីក្រ)មានសុពលភាព?<br>▪ តើមានខ្នងផ្ទះណាខ្លះទៀតមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ(ប័ណ្ណក្រីក្រ)មានសុពលភាព? |
| ១៤ | ខ្នងផ្ទះមានសមាជិកមានពិការភាព | ▪ តើខ្នងផ្ទះណាខ្លះមានសមាជិកមានពិការភាព?<br>▪ តើមានខ្នងផ្ទះណាខ្លះដទៃទៀតមានសមាជិកមានពិការភាព? |

- លេខាកត់ត្រា ជាអ្នកសរសេរលេខសូចនាករបញ្ហា (២ខ្ទង់ ដោយប្រើប៊ិកពណ៌ក្រហម) លើខ្នងផ្ទះដែលមានបញ្ហាត្រូវនឹងសូចនាករនោះនៅក្នុងផែនទីសេវាសង្គម។ ឧទាហរណ៍ បើសួរលើសូចនាករលេខ០៥ លេខាកត់ត្រាត្រូវសរសេរលេខ ០៥ ដោយប្រើប៊ិកពណ៌ក្រហម នៅលើខ្នងផ្ទះណាដែលគ្មានបង្គន់អនាម័យប្រើប្រាស់។ លេខាកត់ត្រា ជាអ្នកគូសសញ្ញា(√)ចូលក្នុងទម្រង់២។
- មេភូមិ បូកសរុប ថ្លែងអំណរគុណ និងបិទអង្គប្រជុំ។

## គ). ជំហានទី៣៖ ប្រមូលព័ត៌មានបន្ថែម និងបូកសរុបព័ត៌មានផែនទីសេវាសង្គមភូមិ

- ក្នុងករណីដែលមិនទាន់ទទួលបានព័ត៌មានសូចនាករបញ្ហាគ្រប់គ្រាន់នៅលើផែនទីសេវាសង្គមក្នុងទម្រង់៣ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវបន្តប្រមូល និងបញ្ចូលព័ត៌មានបន្ថែមតាមខ្នងផ្ទះនីមួយៗ
- មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ប្រជុំបូកសរុបព័ត៌មានសេវាសង្គមដោយប្រើប្រាស់ទម្រង់ ២ និងនៅចុងបញ្ចប់នៃការធ្វើផែនទីសេវាសង្គម គេនឹងបូកសរុបបាននូវព័ត៌មានសេវាសង្គមដែលមានលក្ខណៈពេញលេញដូចមានគំរូបង្ហាញនៅក្នុងទម្រង់ ៣ ជាឧទាហរណ៍មានស្រាប់ដូចខាងក្រោម៖

## ទម្រង់៣៖

### តារាងទិន្នន័យសេវាសង្គមភូមិ
### ភូមិចាអ៊ុងកៅ ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគិរី

| លេខកូដខ្នងផ្ទះ (១) | ឈ្មោះមេខ្នងផ្ទះ (២) | សូចនាករសេវាសង្គម (៣) (គូសសញ្ញា √ ចំពោះខ្នងផ្ទះដែលត្រូវនឹងសូចនាករបញ្ហានីមួយៗ) | | | | | | | | | | | | | | សរុប (៤) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ០១ | ០២ | ០៣ | ០៤ | ០៥ | ០៦ | ០៧ | ០៨ | ០៩ | ១០ | ១១ | ១២ | ១៣ | ១៤ | |
| ០០១ | សំ ញៀន | √ | | | | √ | | √ | √ | | | | | | | ៤ |
| ០០២ | អ៊ុក ផា | √ | | | | | √ | | | √ | | √ | | √ | | ៥ |
| ០០៣ | ហេង សំរិត | √ | | | | | √ | | √ | | √ | | | | | ៤ |
| ០០៤ | ហ៊ាង ចំរើន | √ | | | | | √ | | | | | √ | | | | ៣ |
| ០០៥ | កុយ សុភ័ក្រ្ត | | | | √ | √ | √ | | | √ | | √ | | | √ | ៦ |
| ....... | .............. | | | | √ | | √ | √ | | | | √ | | | | ៤ |
| ....... | .............. | | | | √ | √ | √ | √ | | √ | | | √ | √ | | ៧ |
| ១១១ | គា កុម្ភៈ | | | | | √ | | | | | | | | | | ១ |
| សរុប | | ៤ | ០ | ០ | ៣ | ៤ | ៦ | ៣ | ២ | ៣ | ១ | ៤ | ១ | ២ | ១ | |

- បើសូចនាករបញ្ហាណា ដែលមានខ្នងផ្ទះសរុបច្រើនជាងគេ (មើលក្នុងជួរផ្តេកក្រោមគេបំផុត- សរុបខ្នងផ្ទះតាមសូចនាករបញ្ហា នីមួយៗ) មានន័យថាសូចនាករនោះ គឺជាបញ្ហាអាទិភាពខ្លាំងជាងគេដែលក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិត្រូវពិចារណាក្នុងការដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។
- បើខ្នងផ្ទះណាដែលមានចំនួនសរុបសូចនាករបញ្ហាច្រើនជាងគេ(មើលក្នុងកូឡោនទី៤) ឬមានតម្រូវការជំនួយបន្ទាន់ មានន័យថាខ្នងផ្ទះនោះមានភាពងាយរងគ្រោះដែលក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិ ត្រូវពិចារណាក្នុងការផ្តល់អាទិភាពខ្ពស់ជាងគេសម្រាប់កំណត់ជាក្រុមគោលដៅក្នុងការទទួលសេវាសង្គម។
- ភូមិអាចបន្ថែមសូចនាករថ្មីបានតាមការចាំបាច់ និងតម្រូវការរបស់ដៃគូអភិវឌ្ឍន៍នានា។

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....

ភូមិ............ថ្ងៃទី.......... ខែ....... ឆ្នាំ........

មេភូមិ

## ឃ). ជំហាន៤៖ ការបូកសរុបទិន្នន័យសេវាសង្គមឃុំ សង្កាត់

- ប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំថ្នាក់ឃុំ សង្កាត់ ដើម្បីបូកសរុបទិន្នន័យសេវាសង្គម
- មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ គ្រប់ភូមិក្នុងឃុំសង្កាត់ យកផែនទីសេវាសង្គម ដែលបានគូស និងលទ្ធផលបូកសរុបទិន្នន័យសេវាសង្គមភូមិ (ទម្រង់៣) មករាយការណ៍ជូនកិច្ចប្រជុំថ្នាក់ឃុំ សង្កាត់
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ពិនិត្យមើលព័ត៌មានលើផែនទីសេវាសង្គមភូមិ និងលទ្ធផលបូកសរុបទិន្នន័យសេវាសង្គមភូមិពីគ្រប់ភូមិដែលបានរាយការណ៍។ ក្នុងករណីដែលពិនិត្យឃើញមានភាពមិនស៊ីសង្វាក់គ្នារវាងព័ត៌មានលើផែនទីសេវាសង្គមភូមិ និងក្នុងទម្រង់ ៣ ត្រូវធ្វើការកែតម្រូវជាមួយមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិសាមីនីមួយៗ។
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ធ្វើការបូកសរុបទិន្នន័យសេវាសង្គមភូមិពីគ្រប់ភូមិទាំងអស់ក្នុងទម្រង់ ៣ ហើយបញ្ចូលទៅក្នុងទម្រង់ ៤ ដូចមានជាឧទាហរណ៍ខាងក្រោម៖

## ទម្រង់៤៖

### តារាងបូកសរុបទិន្នន័យសេវាសង្គមឃុំ សង្កាត់
### ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគិរី

| ល.រ (១) | ឈ្មោះភូមិ (២) | ចំនួនខ្នងផ្ទះ | សូចនាករសេវាសង្គម (៣) (ស្រង់យកចំនួនខ្នងផ្ទះសរុបតាមសូចនាករបញ្ហានីមួយៗពីទម្រង់១) | | | | | | | | | | | | | | សរុប (៤) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ០១ | ០២ | ០៣ | ០៤ | ០៥ | ០៦ | ០៧ | ០៨ | ០៩ | ១០ | ១១ | ១២ | ១៣ | ១៤ | |
| ១ | ចាអ៊ុងកៅ | ១១១ | ៤ | ០ | ០ | ៣ | ៣ | ៤ | ២ | ៣ | ២ | ១ | ៤ | ២ | ៣ | ១ | ៣២ |
| ២ | ធួយអំពិល | ៨៦ | ១១ | ១៣ | ៥ | ៧ | ១៤ | ៥៩ | ២៣ | ១៣ | ០ | ១ | ១១ | ១៣ | ១ | ១២ | ១៨៣ |
| ៣ | ធួយទុំ | ៦៩ | ១ | ១៤ | ៦ | ៨ | ៦៩ | ៦៩ | ២៤ | ១៤ | ០ | ០ | ៣៨ | ១៤ | ១៤ | ១ | ៣១៥ |
| ៤ | ចាអ៊ុងកេត | ៥២ | ៦ | ១ | ៧ | ៩ | ៣៨ | ៤៨ | ២ | ១២ | ០ | ០ | ២០ | ១ | ៤ | ០ | ១៤៨ |
| ៥ | ចាអ៊ុងចាន់ | ១០៦ | ៦ | ១ | ៧ | ៩ | ៧ | ៨០ | ១៥ | ១ | ០ | ៩ | ២៤ | ១ | ១០ | ៦ | ១៧៦ |
| សរុប | | ៤២៤ | ២៨ | ២៩ | ២៥ | ៣៦ | ១៤៥ | ២៨៩ | ៦៦ | ៤៣ | ២ | ១១ | ៩៧ | ៣១ | ៣២ | ២០ | |
| **ចំណាត់ថ្នាក់អាទិភាពសូចនាករបញ្ហា** | | | **១០** | **៩** | **១១** | **៦** | **២** | **១** | **៤** | **៥** | **១៤** | **១៣** | **៣** | **៨** | **៧** | **១២** | |

- បើសូចនាករបញ្ហាណាដែលមានខ្នងផ្ទះសរុបច្រើនជាងគេ (មើលក្នុងជួរផ្តេកសរុបខ្នងផ្ទះតាមសូចនាករបញ្ហានីមួយៗ) មានន័យថាសូចនាករនោះគឺជាបញ្ហាអាទិភាពខ្លាំងជាងគេ ដែលក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិត្រូវពិចារណាក្នុងការដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។
- បើខ្នងផ្ទះណាដែលមានចំនួនសរុបសូចនាករបញ្ហាច្រើនជាងគេ (មើលក្នុងកូឡោនទី៤) ឬ មានតម្រូវការជំនួយបន្ទាន់ មានន័យថាខ្នងផ្ទះនោះមានភាពងាយរងគ្រោះដែលក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិ ត្រូវពិចារណាក្នុងការផ្តល់អាទិភាពខ្ពស់ជាងគេសម្រាប់កំណត់ជាក្រុមគោលដៅក្នុងការទទួលសេវាសង្គម។

| | |
|---|---|
| បានឃើញ និង ឯកភាព | ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥..... |
| ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥..... | ថ្ងៃទី....... ខែ....... ឆ្នាំ........ |
| ថ្ងៃទី....... ខែ....... ឆ្នាំ........ | អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ |
| ប្រធាន គ.ក.ន.ក | |

### ង). ការធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គមភូមិ

ការធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គម ត្រូវធ្វើឡើងនៅរៀងរាល់ឆ្នាំ ក្នុងគោលបំណងតាមដានវឌ្ឍនភាព និងស្វែងរកបញ្ហានានាដែលត្រូវដោះស្រាយ ដើម្បីដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់នៅឆ្នាំបន្ទាប់។ ការធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គមត្រូវចាប់អនុវត្តពី ជំហាន១ រហូតដល់ជំហាន ៣ ឡើងវិញ។

## ១.៣. ការរៀបចំតារាងវិភាគបញ្ហា តម្រូវការ និងដំណោះស្រាយ

- ប្រធាន គ.ក.ន.ក ត្រូវដឹកនាំ និងសម្របសម្រួលការប្រជុំដោយមានការចូលរួមពីគណៈកម្មាធិការកសាងផែនការ និងថវិកា (គ.ផ.ថ) និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដោយមានការជួយបច្ចេកទេសពីមន្ត្រីការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់
- អង្គប្រជុំពិនិត្យ និងស្រង់អាទិភាពនៃសូចនាករទៅក្នុងកូឡោនបញ្ហាក្នុងទម្រង់៥តារាងវិភាគបញ្ហាតម្រូវការនិងដំណោះស្រាយដោយផ្អែកតាមព័ត៌មានសេវាសង្គមឃុំ សង្កាត់ដែលបានបូកសរុបរួចក្នុងទម្រង់៤
- ជាមួយគ្នានេះផងដែរអង្គប្រជុំបន្តការពិភាក្សាទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយរួចបញ្ចូលក្នុងទម្រង់៥ តារាងវិភាគបញ្ហាតម្រូវការ និងដំណោះស្រាយ ដូចមានជាឧទាហរណ៍ខាងក្រោម
- ប្រធាន គ.ក.ន.ក ត្រូវបន្តដឹកនាំ និងសម្របសម្រួលការពិភាក្សារៀបចំតម្រូវការគម្រោង ឬសកម្មភាពសេវាសង្គមអាទិភាព ដោយយកពីកូឡោនដំណោះស្រាយក្នុងទម្រង់៥ ដើម្បីរៀបចំឈ្មោះសកម្មភាពក្នុងទម្រង់៦
- មេឃុំ ចៅសង្កាត់ ត្រូវណែនាំឱ្យ គ.ផ.ថ ពិនិត្យ និងដាក់បញ្ចូលបញ្ហាតម្រូវការ ដែលទទួលបានពីកិច្ចប្រជុំខាងលើនេះទៅក្នុងដំណើរការនៃការរៀបចំតម្រូវការគម្រោងអាទិភាពរបស់ឃុំ សង្កាត់
- គ.ផ.ថ ពិនិត្យ និងឯកភាពទៅលើតម្រូវការសកម្មភាពសេវាសង្គមអាទិភាពដែលត្រូវស្នើប្រើប្រាស់មូលនិធិឃុំ សង្កាត់។

# ទម្រង់៥៖

## តារាងវិភាគបញ្ហា តម្រូវការ និងដំណោះស្រាយ

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុនៃបញ្ហា |
|---|---|---|
| ស្ត្រីមានផ្ទៃពោះសរុបចំនួន ២៩ ខ្នងផ្ទះ នៅក្នុងឃុំមិនបានសម្រាលកូននៅមូលដ្ឋានសុខាភិបាល | ជួយទុំ<br>ជួយអំពិល<br>ចាអ៊ុងកេត<br>ចាអ៊ុងចាន់<br>ចាអ៊ុងកៅ | ▪ មណ្ឌលសុខភាពនៅឆ្ងាយ<br>▪ ស្ថានភាពគ្រួសារក្រីក្រ<br>▪ មិនយល់ពីសារៈសំខាន់នៃការសម្រាលកូនដោយសុវត្ថិភាព |
| ២៨៥ ក្នុងចំណោម ៤២៤ ខ្នងផ្ទះនៅក្នុងឃុំ គ្មានទឹកស្អាតប្រើប្រាស់ | ជួយទុំ<br>ចាអ៊ុងចាន់<br>ជួយអំពិល<br>ចាអ៊ុងកេត | អណ្តូងស្នប់ខូច គ្មានឧបករណ៍ស្តុកទឹកសម្រាប់ ប្រើប្រាស់ |
| ១៤៥ ក្នុងចំណោម ៤២៤ ខ្នងផ្ទះក្នុងឃុំ គ្មានបង្គន់អនាម័យ | ជួយទុំ<br>ចាអ៊ុងកេត<br>ជួយអំពិល<br>ចាអ៊ុងចាន់ | មិនយល់ពីសារៈសំខាន់នៃការប្រើបង្គន់អនាម័យ ខ្វះថវិកាសម្រាប់សង់បង្គន់ |
| ៩៧ ក្នុងចំណោម៤២៤ខ្នងផ្ទះមានកុមារអាយុ៣-៥ឆ្នាំ មិនបានចូលរៀនមត្តេយ្យ | ជួយទុំ<br>ចាអ៊ុងចាន់<br>ចាអ៊ុងកេត<br>ជួយអំពិល | គ្មានគ្រូមត្តេយ្យ |
| ៧០ ក្នុងចំណោម៤២៤ខ្នងផ្ទះ នៅក្នុងឃុំ មានកុមារមកពីមណ្ឌលកុមាកំព្រាមកនៅជាមួយគ្រួសារវិញ | ជួយទុំ<br>ចាអ៊ុងចាន់<br>ជួយអំពិល<br>ចាអ៊ុងកេត | ពិបាករស់នៅក្នុងមណ្ឌលកុមារកំព្រា |

| តម្រូវការ | ដំណោះស្រាយ | ផ្សេងៗ |
|---|---|---|
| សម្រាលកូន ដោយសុវត្ថិភាព | ▪ ផ្តល់ប្រាក់ឧបត្ថម្ភ ឬថ្លៃធ្វើដំណើរសម្រាប់ស្ត្រីមានផ្ទៃពោះ<br>▪ ផ្សព្វផ្សាយពីសារៈសំខាន់នៃការសម្រាលកូនដោយសុវត្ថិភាព | |
| មានទឹកស្អាតសម្រាប់ប្រើប្រាស់ | ▪ ជួសជុលអណ្តូងស្នប់<br>▪ សាងសង់អណ្តូងស្នប់<br>▪ ផ្តល់ធុងចម្រោះ<br>▪ តភ្ជាប់បណ្តាញទឹកស្អាត | |
| មានបង្គន់អនាម័យសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ | ▪ ផ្សព្វផ្សាយពីការប្រើប្រាស់បង្គន់អនាម័យ<br>▪ ផ្តល់សម្ភារសម្រាប់ការសាងសង់ | |
| មានគ្រូមត្តេយ្យដើម្បីដំណើរការបង្រៀនថ្នាក់មត្តេយ្យ | ▪ ផ្តល់កិច្ចសន្យាគ្រូមត្តេយ្យសហគមន៍ | |
| ជួយគាំទ្រដល់គ្រួសារ កុមារឱ្យមានលទ្ធភាពក្នុងការរស់នៅជួបជុំគ្នាប្រកបដោយសុភមង្គល | ▪ ផ្តល់ការគាំទ្រដល់គ្រួសារដែលមានកុមារបានមកនៅជាមួយគ្រួសារវិញ | |

# ទម្រង់ទី៦៖

## តម្រូវការសកម្មភាពអាទិភាព

| ល.រ | ឈ្មោះសកម្មភាព | ទីតាំង | លទ្ធផល | | រយៈពេល | អ្នកទទួលផល | | តម្លៃប៉ាន់ស្មាន (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| ១ | ផ្តល់ប្រាក់ឧបត្ថម្ភ ឬថ្លៃធ្វើដំណើរសម្រាប់ស្ត្រីមានផ្ទៃពោះដែលងាយរងគ្រោះទៅប្រើប្រាស់សេវាពិនិត្យផ្ទៃពោះ និងសម្រាលកូននៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក | ជួយអំពិល ចាអ៊ុងកេត ចាអ៊ុងចាន់ ចាអ៊ុងកៅ | ៥ | នាក់ | ១២ ខែ | ៥ | ៥ | ២០០.០០០ | |
| ២ | ផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារដែលងាយរងគ្រោះបំផុត (ជួសជុលអណ្តូងទឹក ភ្ជាប់បណ្តាញទឹកស្អាតសម្រាប់គ្រួសារក្រីក្រ) | ជួយទុំ ចាអ៊ុងចាន់ ជួយអំពិល ចាអ៊ុងកេត | ១១ | គ្រួសារ | ១២ ខែ | ៥៥ | ៣១ | ៤៤០.០០០ | |
| ៣ | ផ្សព្វផ្សាយអប់រំមាតាបិតា ធ្វើចលនាសហគមន៍ និងសកម្មភាព សេវាមូលដ្ឋានស្តីពីសារៈសំខាន់នៃការប្រើប្រាស់បង្គន់អនាម័យ | ជួយទុំ ចាអ៊ុងកេត ជួយអំពិល ចាអ៊ុងចាន់ | ៤ | វគ្គ | ១២ខែ | ២០០ | ១៤៥ | ៥៥២.០០០ | |
| ៤ | សាងសង់បង្គន់អនាម័យដល់គ្រួសារដែលងាយរងគ្រោះបំផុត | ជួយទុំ ចាអ៊ុងកេត ជួយអំពិល ចាអ៊ុងចាន់ | ២០ | គ្រួសារ | ១២ ខែ | ២០០ | ១៤៥ | ១.៦០០.០០០ | |
| ៥ | ផ្តល់កិច្ចសន្យាគ្រូមត្តេយ្យសហគមន៍ | ជួយទុំ ចាអ៊ុងចាន់ | ២ | នាក់ | ១២ ខែ | ៥០ | ៣៨ | ១២.០០០.០០០ | |
| ៦ | ផ្គត់ផ្គង់សម្ភាររៀន និងបង្រៀន សម្ភារទឹកស្អាត និងអនាម័យដល់មត្តេយ្យសហគមន៍ | ជួយទុំ ចាអ៊ុងចាន់ | ២ | សាលា | ១២ ខែ | ៥០ | ៣៨ | ២០០.០០០ | |
| ៧ | ផ្តល់ការគាំទ្រដល់គ្រួសារដែលមានកុមារដែលបានមករួមរស់ជាមួយគ្រួសារវិញ | ជួយទុំ ចាអ៊ុងកេត ជួយអំពិល ចាអ៊ុងចាន់ | ៧ | នាក់ | ១២ ខែ | ៧ | ៥ | ៣.៣៦០.០០០ | |

# ជំពូកទី២

# ការរៀបចំផែនការ សកម្មភាព និងថវិកា

ជំពូកនេះនិយាយអំពីការរៀបចំផែនការសកម្មភាព និងថវិកាសេវាសង្គម ដើម្បីឆ្លើយ
តបទៅនឹងតម្រូវការអាទិភាពក្នុងជំពូក១។



គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ប្រជុំ វិភាគ និងរៀបចំផែនការសកម្មភាពសេវាសង្គម ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគិរី

© UNICEF Cambodia /2017/Antoine Raab

## ២.១. ការរៀបចំផែនការសកម្មភាព និងថវិកាសេវាសង្គមប្រចាំឆ្នាំ

មេឃុំ ចៅសង្កាត់ត្រូវណែនាំអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ក្នុងការពិនិត្យសកម្មភាពជាអាទិភាពផ្នែកសេវាសង្គមនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់ (ក្រោយសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក) ដើម្បីរៀបចំផែនការសកម្មភាពសេវាសង្គមប្រចាំឆ្នាំ (ទម្រង់៧)។

មេឃុំ ចៅសង្កាត់ត្រូវណែនាំស្មៀនឃុំ សង្កាត់ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ក្នុងការរៀបចំផែនការថវិកាសេវាសង្គមប្រចាំឆ្នាំ ដោយផ្អែកតាមផែនការសកម្មភាពសេវាសង្គមប្រចាំឆ្នាំ (ទម្រង់៨)។

មេឃុំ ចៅសង្កាត់ត្រូវដាក់ផែនការសកម្មភាពសេវាសង្គមប្រចាំឆ្នាំ (ទម្រង់៧) និងផែនការថវិកាសេវាសង្គមប្រចាំឆ្នាំ(ទម្រង់៨) ជូនកិច្ចប្រជុំ គ.ក.ន.ក ពិនិត្យ និងអនុម័ត។

## ២.២. ការរៀបចំផែនការសកម្មភាព និងថវិកាសេវាសង្គមប្រចាំត្រីមាស

មេឃុំ ចៅសង្កាត់ត្រូវណែនាំអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ក្នុងការរៀបចំផែនការសកម្មភាពសេវាសង្គមប្រចាំត្រីមាស (ទម្រង់៩) និងផែនការថវិកាសេវាសង្គមប្រចាំត្រីមាស (ទម្រង់១០) ដោយផ្អែកតាមផែនការសកម្មភាពសេវាសង្គមប្រចាំឆ្នាំ និងផែនការថវិកាសេវាសង្គមប្រចាំឆ្នាំ។

# ទម្រង់៧៖

ជំពូកទី២

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ៖ រតនគិរី
ស្រុក ៖ អូរជុំ
ឃុំ ៖ ចាអ៊ុង

## ផែនការសកម្មភាពសេវាសង្គមប្រចាំឆ្នាំ ២០១៧

| ល.រ | សកម្មភាព | លទ្ធផលគ្រោង | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | ខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១ | ផ្តល់ប្រាក់ឧបត្ថម្ភ ឬថ្លៃធ្វើដំណើរសម្រាប់ស្ត្រីមានផ្ទៃពោះដែលងាយរងគ្រោះទៅប្រើប្រាស់សេវាពិនិត្យផ្ទៃពោះ និងសម្រាលកូននៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក | នាក់ | ៥ | ជួយអំពិល ចាអ៊ុងកេត ចាអ៊ុងចាន់ ចាអ៊ុងកៅ | ៥ | ៥ | x | | | x | x | x | x | X | x | x | x | X |
| ២ | ផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារដែលងាយរងគ្រោះបំផុត(ជួសជុលអណ្តូងទឹក ភ្ជាប់បណ្តាញទឹកស្អាតសម្រាប់គ្រួសារក្រីក្រ) | គ្រួសារ | ១១ | ជួយទុំ ចាអ៊ុងចាន់ ជួយអំពិល ចាអ៊ុងកេត | ៥៥ | ៣១ | | x | x | | | | | | | | | x |
| ៣ | ផ្សព្វផ្សាយអប់រំមាតាបិតាធ្វើចលនាសហគមន៍ និងសកម្មភាពសេវាមូលដ្ឋានស្តីពីសារៈសំខាន់នៃការប្រើប្រាស់បង្គន់អនាម័យ | វគ្គ | ៤ | ជួយទុំ ចាអ៊ុងកេត ជួយអំពិល ចាអ៊ុងចាន់ | ២០០ | ១៤៥ | x | x | x | x | x | x | x | x | x | x | x | x |
| ៤ | ផ្តល់កិច្ចសន្យាគ្រូមត្តេយ្យសហគមន៍ | នាក់ | ២ | ជួយទុំ ចាអ៊ុងចាន់ | ២ | ២ | x | X | x | x | x | x | x | x | x | x | x | x |
| ៥ | ផ្គត់ផ្គង់សម្ភារៀន និងបង្រៀន សម្ភារទឹកស្អាត និងអនាម័យដល់មត្តេយ្យសិក្សាសហគមន៍ | សាលា | ២ | ជួយទុំ ចាអ៊ុងចាន់ | ៥០ | ៣៨ | | X | | x | x | x | x | x | x | x | x | x |

| ល.រ | សកម្មភាព | លទ្ធផលគ្រោង | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | ខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ៦ | ផ្តល់ការគាំទ្រដល់គ្រួសារដែលមានកុមារបានមករួមរស់ជាមួយគ្រួសារវិញ | គ្រួសារ | ៧ | ជួយទុំ ចាអ៊ីងកេត ជួយអំពិល ចាអ៊ីងចាន់ | ២១ | ១៤ | x | X | x | x | x | x | x | x | x | x | x | x |
| ៧ | តាមដានការអនុវត្តសកម្មភាពសេវាសង្គម | ខែ | ១២ | គ្រប់ភូមិ | - | - | x | X | x | x | x | x | x | x | x | x | x | x |
| ៨ | កិច្ចដំណើរការ និងការប្រជុំរបស់ ក.គ.ន.ក | ប្រជុំ | ១២ | សាលាឃុំចាអ៊ីង | ២៤០ | ១៨០ | x | X | x | x | x | x | x | x | x | x | x | x |

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........
មេឃុំ

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........
អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ

## ទម្រង់៨៖



# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត ៖ *រតនគិរី*
ស្រុក ៖ *អូរជុំ*
ឃុំ ៖ *ចាអ៊ុង*

## ផែនការថវិកាសេវាសង្គមប្រចាំឆ្នាំ២០១៧

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃឯកតា (រៀល) | តម្លៃសរុប (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | ផ្តល់ប្រាក់ឧបត្ថម្ភ ឬថ្លៃធ្វើដំណើរសម្រាប់ស្ត្រីមានផ្ទៃពោះដែលងាយរងគ្រោះ ទៅប្រើប្រាស់សេវាពិនិត្យផ្ទៃពោះ និងសម្រាលកូននៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក | នាក់ | ៥ | ៤០.០០០ | ២០០.០០០ | |
| ២ | ផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារដែលងាយរងគ្រោះបំផុត (ជួសជុលអណ្តូងទឹកភ្ជាប់បណ្តាញទឹកស្អាតសម្រាប់គ្រួសារក្រីក្រ) | គ្រួសារ | ១១ | ៤០.០០០ | ៤៤០.០០០ | |
| ៣ | ផ្សព្វផ្សាយនិងអប់រំមាតាបិតា ធ្វើចលនាសហគមន៍ និងសកម្មភាពសេវាមូលដ្ឋានស្តីពីសារៈសំខាន់នៃការប្រើប្រាស់បង្គន់អនាម័យ | | | | ៥៥២.០០០ | |
| ៣.១ | អាហារសម្រន់ | នាក់ | ២០០ | ១.០០០ | ២០០.០០០ | |
| ៣.២ | សម្ភារ និងឯកសារសម្រាប់ផ្សព្វផ្សាយអប់រំ | វគ្គ | ៤ | ៤០.០០០ | ១៦០.០០០ | |
| ៣.៣ | ថ្លៃធ្វើដំណើររបស់ ក.គ.ន.ក (៤នាក់ ៤វគ្គ) | នាក់/វគ្គ | ១៦ | ១២.០០០ | ១៩២.០០០ | |
| ៤ | ផ្តល់កិច្ចសន្យាគ្រូមត្តេយ្យសហគមន៍ ២នាក់ | នាក់/ខែ | ២៤ | ៥០០.០០០ | ១២.០០០.០០០ | |
| ៥ | ផ្គត់ផ្គង់សម្ភាររៀន និងបង្រៀន សម្ភារទឹកស្អាត និងអនាម័យដល់មត្តេយ្យសិក្សាសហគមន៍ | សាលា | ២ | ១០០.០០០ | ២០០.០០០ | |
| ៦ | ផ្តល់ការគាំទ្រដល់គ្រួសារ ដែលមានកុមារបានមករួមរស់ជាមួយគ្រួសារវិញ (៧ គ្រួសារ, ១២ខែ) | គ្រួសារ/ខែ | ៨៤ | ៤០.០០០ | ៣.៣៦០.០០០ | |
| ៧ | តាមដានការអនុវត្តសកម្មភាពសេវាសង្គម | | | | ១៩២.០០០ | |
| ៧.១ | ថ្លៃធ្វើដំណើររបស់គ.ក.ន.ក (២នាក់ ១២ខែ) | នាក់/ខែ | ២៤ | ៨.០០០ | ១៩២.០០០ | |

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃឯកតា (រៀល) | តម្លៃសរុប (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៨ | កិច្ចដំណើរការ និងការប្រជុំ របស់ គ.ក.ន.ក | | | | ៨៤០.០០០ | |
| ៨.១ | អាហារសម្រន់ | ប្រជុំ | ១២ | ៤០.០០០ | ៤៨០.០០០ | |
| ៨.២ | សម្ភារ និងឯកសារ | ខែ | ១២ | ២០.០០០ | ២៤០.០០០ | |
| ៨.៣ | ថ្លៃធ្វើដំណើរសម្រាប់ គ.ក.ន.ក ទៅប្រជុំ នៅឃុំសង្កាត់ ស្រុក ក្រុង ឬខណ្ឌ | រួម | ១ | ១២០.០០០ | ១២០.០០០ | |
| **សរុបរួម** | | | | | **១៧.៧៨៤.០០០** | |

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........
មេឃុំ

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........
ស្មៀនឃុំ

## ទម្រង់៩៖

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត ៖ *រតនគិរី*

ស្រុក ៖ *អូរជុំ*

ឃុំ ៖ *ចាអ៊ុង*

## ផែនការសកម្មភាពសេវាសង្គមប្រចាំត្រីមាសទី១ (មករា-មីនា) ឆ្នាំ ២០១៧

| ល.រ | សកម្មភាព | លទ្ធផលរំពឹងទុក | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | ខែមករា | | | | ខែកុម្ភៈ | | | | ខែមីនា | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | |
| ១ | ផ្តល់ប្រាក់ឧបត្ថម្ភឬថ្លៃធ្វើដំណើរសម្រាប់ស្ត្រីមានផ្ទៃពោះដែលងាយរងគ្រោះទៅប្រើប្រាស់សេវាពិនិត្យផ្ទៃពោះ និងសម្រាលកូននៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក | នាក់ | ២ | ជួយអំពិល ចាអ៊ុងកេត ចាអ៊ុងចាន់ ចាអ៊ុងកៅ | ២ | ២ | | | x | x | | | | | | | | | ▪ គ.ក.ន.ក ▪ មណ្ឌលសុខភាព |
| ២ | ផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារដែលងាយរងគ្រោះបំផុត(ជួសជុលអណ្តូងទឹកភ្ជាប់ បណ្តាញទឹកស្អាតសម្រាប់ គ្រួសារក្រីក្រ) | គ្រួសារ | ៣ | ជួយទុំ ចាអ៊ុងចាន់ ជួយអំពិល ចាអ៊ុងកេត | ១៧ | ១២ | | | | | x | x | x | x | x | x | x | x | ▪ ក្រុមប្រឹក្សាឃុំ ▪ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |
| ៣ | ផ្សព្វផ្សាយ និងអប់រំមាតាបិតាធ្វើចលនាសហគមន៍ និងសកម្មភាពសេវាមូលដ្ឋានស្តីពីសារៈសំខាន់នៃការប្រើប្រាស់បង្គន់អនាម័យ | វគ្គ | ៤ | ជួយទុំ ចាអ៊ុងកេត ជួយអំពិល ចាអ៊ុងចាន់ | ៥០ | ៣៥ | | | | x | | | x | | x | | | x | ▪ គ.ក.ន.ក ▪ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |
| ៤ | ផ្តល់កិច្ចសន្យា និងផ្តល់ប្រាក់ខែគ្រូមត្តេយ្យសហគមន៍ | នាក់ | ២ | ជួយទុំ ចាអ៊ុងចាន់ | ៥០ | ៣៨ | x | x | x | x | x | x | x | x | x | x | x | x | ▪ ក្រុមប្រឹក្សា ▪ ការិយាល័យអប់រំស្រុក |
| ៥ | ផ្គត់ផ្គង់សម្ភាររៀន និងបង្រៀន សម្ភារទឹកស្អាតនិងអនាម័យដល់មត្តេយ្យសិក្សាសហគមន៍ | សាលា | ២ | ជួយទុំ ចាអ៊ុងចាន់ | ៥០ | ៣៨ | | | | | | | x | x | | | | | ▪ ក្រុមប្រឹក្សា ▪ ការិយាល័យអប់រំស្រុក |

| ល.រ | សកម្មភាព | លទ្ធផលរំពឹងទុក | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | ខែមករា | | | | ខែកុម្ភៈ | | | | ខែមីនា | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | |
| ៦ | ផ្តល់ការគាំទ្រដល់គ្រួសារដែលមានកុមារបានមករួមរស់ជាមួយគ្រួសារវិញ | គ្រួសារ | ៧ | ធួយទុំ ចាអ៊ីងកេត ធួយអំពិល | ២១ | ១៤ | x | x | x | x | x | x | x | x | x | x | x | x | គ.ក.ន.ក |
| ៧ | ការតាមដានការអនុវត្តសកម្មភាពសេវាសង្គម | ខែ | ៣ | គ្រប់ភូមិ | | | x | x | x | x | x | x | x | x | x | x | x | x | គ.ក.ន.ក |
| ៨ | កិច្ចប្រជុំប្រចាំខែរបស់ គ.ក.ន.ក | ខែ | ៣ | សាលាឃុំ | | | | | | x | | | | x | | | | x | គ.ក.ន.ក |

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........
មេឃុំ

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........
អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ

## ទម្រង់១០៖

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ៖ *រតនគិរី*

ស្រុក ៖ *អូរជុំ*

ឃុំ ៖ *ចាអ៊ុង*

## ផែនការថវិកាប្រចាំត្រីមាសទី១ (មករា-មីនា) ឆ្នាំ ២០១៧

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃឯកតា (រៀល) | តម្លៃសរុប (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | ផ្តល់ប្រាក់ឧបត្ថម្ភ ឬថ្លៃធ្វើដំណើរសម្រាប់ស្ត្រីមានផ្ទៃពោះដែលងាយរងគ្រោះទៅប្រើប្រាស់សេវាពិនិត្យផ្ទៃពោះ និងសម្រាលកូន នៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក | នាក់ | ២ | ៤០.០០០ | ៨០.០០០ | |
| ២ | ផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារដែលងាយរងគ្រោះបំផុត (ជួសជុលអណ្តូងទឹក ភ្ជាប់បណ្តាញទឹកស្អាតសម្រាប់គ្រួសារក្រីក្រ) | គ្រួសារ | ៣ | ៤០.០០០ | ១២០.០០០ | |
| ៣ | ផ្សព្វផ្សាយអប់រំមាតាបិតា ធ្វើចលនាសហគមន៍ និងសកម្មភាពសេវាមូលដ្ឋានស្តីពីសារៈសំខាន់នៃការប្រើប្រាស់បង្គន់អនាម័យ | | | | ១៧២.០០០ | |
| ៣.១ | អាហារសម្រន់ | នាក់ | ៥០ | ២.០០០ | ១០០.០០០ | |
| ៣.២ | សម្ភារ និងឯកសារសម្រាប់ផ្សព្វផ្សាយអប់រំ | វគ្គ | ១ | ៤០.០០០ | ៤០.០០០ | |
| ៣.៣ | ថ្លៃធ្វើដំណើររបស់ ក.គ.ន.ក (៤នាក់) | នាក់/វគ្គ | ៤ | ៨.០០០ | ៣២.០០០ | |
| ៤ | ផ្តល់កិច្ចសន្យាគ្រូមត្តេយ្យសហគមន៍ចំនួន២នាក់ | នាក់ | ៦ | ៥០០.០០០ | ៣.០០០.០០០ | |
| ៥ | ផ្គត់ផ្គង់សម្ភាររៀន និងបង្រៀន សម្ភារទឹកស្អាត និងអនាម័យដល់ មត្តេយ្យសិក្សាសហគមន៍ | សាលា | ២ | ១០០.០០០ | ២០០.០០០ | |
| ៦ | ផ្តល់ការគាំទ្រដល់គ្រួសារ ដែលមានកុមារបានមករួមរស់ជាមួយគ្រួសារវិញ | គ្រួសារ | ២១ | ៤០.០០០ | ៨៤០.០០០ | |
| ៧ | តាមដានការអនុវត្តសកម្មភាពសេវាសង្គម | | | | ៤៨.០០០ | |

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃឯកតា (រៀល) | តម្លៃសរុប (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៧.១ | ថ្លៃធ្វើដំណើររបស់ គ.ក.ន.ក (២នាក់ ៣ខែ) | នាក់/ខែ | ៦ | ៨.០០០ | ៤៨.០០០ | |
| ៨ | កិច្ចដំណើរការ និងការប្រជុំរបស់ គ.ក.ន.ក | | | | ២៤០.០០០ | |
| ៨.១ | អាហារសម្រន់ | ប្រជុំ | ៣ | ៤០.០០០ | ១២០.០០០ | |
| ៨.២ | សម្ភារ និងឯកសារ | ខែ | ៣ | ២០.០០០ | ៦០.០០០ | |
| ៨.៣ | ថ្លៃធ្វើដំណើរសម្រាប់ គ.ក.ន.ក ទៅប្រជុំនៅឃុំ សង្កាត់ ស្រុក ក្រុង ឬខណ្ឌ | លើក | ១ | ៦០.០០០ | ៦០.០០០ | |
| **សរុបរួម** | | | | | **៤.៧០០.០០០** | |

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........
មេឃុំ

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........
ស្មៀនឃុំ

# ជំពូកទី៣

## ការអនុវត្ត ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ សកម្មភាពសេវាសង្គម

ជំពូកនេះបរិយាយអំពីការអនុវត្តសកម្មភាព ការប្រើប្រាស់ថវិកា ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃលើសកម្មភាព និងថវិកាសេវាសង្គមដែលបានអនុម័ត។



អ្នកធ្វើការងារសុខភាពចុះតាមដានដល់ផ្ទះប្រជាពលរដ្ឋដើម្បីជានាថាឪពុក ម្តាយនាំកូនទៅចាក់ថ្នាំបង្ការគ្រប់
ភូមិឡៅ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
© UNICEF Cambodia/2017/Fani Laurado

# ៣.១. កិច្ចការសំខាន់ដែលត្រូវធ្វើនៅក្នុងការអនុវត្តសកម្មភាពសេវាសង្គម

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ គឺជាអ្នកទទួលខុសត្រូវសំខាន់នៅក្នុងការអនុវត្តសកម្មភាពសេវាសង្គម និងកិច្ចការចាំបាច់មួយចំនួនពាក់ព័ន្ធនឹងការងារដូចខាងក្រោម៖

- ការប្រើប្រាស់ខ្ទង់ថវិកា
- ការរៀបចំអនុវត្តសកម្មភាពសេវាសង្គម
- ការរៀបចំសំណើថវិកា
- ការទូទាត់ថវិកា

## ៣.១.១. ការប្រើប្រាស់ខ្ទង់ថវិកា

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវមានផែនការថវិកាសេវាសង្គមសម្រាប់ប្រើប្រាស់នៅក្នុងការអនុវត្តសកម្មភាពសេវាសង្គម និងត្រូវយល់ដឹងអំពីមាតិកាចំណាយថវិកាសម្រាប់ប្រើប្រាស់ ដើម្បីស្នើសុំ និងទូទាត់ថវិកាឱ្យបានត្រឹមត្រូវស្របតាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់។

**ការកំណត់មាតិកាថវិកា និងលិខិតយុត្តិការចំណាយសម្រាប់ទូទាត់សេវាសង្គមនៅរដ្ឋបាលឃុំ សង្កាត់ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី១។**

## ៣.១.២. ការរៀបចំអនុវត្តសកម្មភាពសេវាសង្គម

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងត្រីមាស ដែលបានចុះហត្ថលេខារួចពីមេឃុំ ចៅសង្កាត់ ដូចខាងក្រោម៖

- ពិនិត្យមើលផែនការសកម្មភាពសេវាសង្គមប្រចាំត្រីមាស ដែលត្រូវអនុវត្ត និងសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធ
- រៀបចំ និងអនុវត្ត តាមសៀវភៅណែនាំស្ដីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ចំពោះសកម្មភាពទាំងឡាយណាដែលតម្រូវឱ្យអនុវត្តតាមនីតិវិធីចំណាយធម្មតា
- សហការរៀបចំកិច្ចសន្យាជាមួយអ្នកផ្ដល់សេវាកម្ម ដូចជា គ្រូមត្តេយ្យសហគមន៍អ្នកបោសសំអាត និងអ្នកយាមនៅមណ្ឌលសុខភាព និងជំនួយការរដ្ឋបាលឃុំ សង្កាត់ (ទទួលបន្ទុកកិច្ចការសង្គម) ដើម្បីដាក់ជូនមេឃុំ ចៅសង្កាត់ពិនិត្យ និងសម្រេចដូចគំរូឧទាហរណ៍ខាងក្រោម៖

(ឧទាហរណ៍ទម្រង់កិច្ចសន្យាផ្តល់សេវាបង្រៀនមត្តេយ្យសិក្សាសហគមន៍)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត ៖ *រតនគិរី*

ស្រុក ៖ *អូរជុំ*

ឃុំ ៖ *ចាអ៊ុង*

## កិច្ចសន្យាផ្តល់សេវាបង្រៀនមត្តេយ្យសិក្សាសហគមន៍

កិច្ចសន្យានេះធ្វើឡើងនៅថ្ងៃទី*០១* ខែ*មករា* ឆ្នាំ*២០១៨* រវាងឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគិរី ហៅកាត់ថា ភាគី"ក" និងលោកស្រី *អឿន សុភាព* អាយុ *៤៨* ឆ្នាំ អាសយដ្ឋាននៅភូមិជួយទុំ ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគិរី ហៅកាត់ថាភាគី«ខ» **គ្រូមត្តេយ្យសហគមន៍**។

**ភាគីទាំងពីរព្រមព្រៀងគ្នាដូចតទៅ៖**

**១. លក្ខខណ្ឌការងារ**

**ក. ភាគី ‹ខ› នឹងបំពេញការងារជូនដល់ឃុំ សង្កាត់ ដូចខាងក្រោម៖**

- ផ្សព្វផ្សាយប្រតិទិនសិក្សាប្រចាំឆ្នាំរបស់មត្តេយ្យសិក្សាសហគមន៍ដល់មាតាបិតាសិស្ស
- សហការជាមួយអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ក្នុងការអប់រំផ្សព្វផ្សាយ និងចលនាមាតាបិតាបញ្ជូនកូនមករៀន
- រៀបចំចុះឈ្មោះកុមារសម្រាប់ការចូលរៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍
- រៀបចំកិច្ចតែងការបង្រៀនប្រចាំថ្ងៃ សម្រាប់ការបង្រៀន
- បង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ឱ្យបានទៀងទាត់ទៅតាមប្រតិទិន និងពេលវេលាដែលបានឯកភាព
- អនុវត្តវិធីសាស្ត្របង្រៀនទៅតាមការណែនាំរបស់ក្រសួង ឬមន្ទីរអប់រំ យុវជន និងកីឡា
- រៀបចំទុកដាក់សម្ភារ និងឧបករណ៍បង្រៀនឱ្យបានត្រឹមត្រូវ និងគង់វង្ស
- ចូលរួមរៀបចំកម្មវិធីមត្តេយ្យសិក្សាសហគមន៍ ការបណ្តុះបណ្តាល និងសិក្ខាសាលា
- តាមដានត្រួតពិនិត្យ និងចុះវត្តមានរបស់សិស្សប្រចាំថ្ងៃ
- រៀបចំរបាយការណ៍ប្រចាំខែស្តីពីការបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍។

**ខ. ភាគី ‹ខ› នឹងធ្វើការងារក្រោមការគ្រប់គ្រងផ្ទាល់របស់មេឃុំ។**

**គ. ភាគី ‹ខ› នឹងបម្រើការងារនៅក្នុងភូមិជួយទុំ ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគិរី។**

**២. រយៈពេលនៃកិច្ចសន្យា**

កិច្ចសន្យានេះធ្វើឡើងសម្រាប់រយៈពេល១២ខែ ចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

### ៣. ប្រាក់ឧបត្ថម្ភ

ភាគី«ក» នឹងបើកជូនភាគី«ខ» នូវប្រាក់ឧបត្ថម្ភចំនួន ៥០០.០០០ រៀល (ហាសិបម៉ឺនរៀលគត់) ក្នុងមួយខែ។ ការទូទាត់ប្រាក់នឹងធ្វើឡើងនៅដំណាច់ខែនីមួយៗ បន្ទាប់ពី ភាគី«ខ» ដាក់ជូនរបាយការណ៍ប្រចាំខែ ស្តីពីការបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងរបាយការណ៍តាមដានវត្តមានសិស្សប្រចាំខែ។

### ៤. ម៉ោងការងារ

ភាគី«ខ» នឹងបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ចំនួន ៣ម៉ោង ក្នុង១ថ្ងៃ និង ៥ថ្ងៃ ក្នុង១សប្តាហ៍ ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ។ ពេលម៉ោងបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ គឺចាប់ពី ម៉ោង៧ព្រឹក ដល់ម៉ោង១០ព្រឹក និងឬ ចាប់ពីម៉ោង១រសៀល ដល់ម៉ោង ៤រសៀល។

### ៥. ការឈប់សម្រាកបុណ្យជាតិ និងការឈប់សម្រាកពិសេស

ភាគី«ខ» មានសិទ្ធិឈប់សម្រាកបុណ្យជាតិ តាមប្រតិទិនឈប់សម្រាកជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា។

ភាគី«ខ» មានសិទ្ធិឈប់សម្រាកពិសេស ក្នុងឱកាសមានព្រឹត្តិការណ៍ដែលប៉ះពាល់ផ្ទាល់ដល់គ្រួសារនៃបុគ្គលិកនោះ។

ចំពោះភាគី«ខ» ជាស្ត្រីមានសិទ្ធិឈប់សម្រាកលំហែមាតុភាពរយៈពេល០៣ខែដោយទទួលបាននូវប្រាក់ឧបត្ថម្ភប្រចាំខែ។

### ៦. ការបញ្ចប់កិច្ចសន្យា

ភាគីណាមួយក៏អាចបញ្ចប់កិច្ចសន្យានេះពេលណាក៏បាន ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតចំនួន៣០ថ្ងៃជាមុន។

ក្នុងករណីត្រូវបានបណ្តេញចេញពីការងារដោយសារការប្រព្រឹត្តកំហុសធ្ងន់ធ្ងរ កិច្ចសន្យាត្រូវបញ្ចប់ដោយចូលជាធរមានភ្លាម។

### ៧. ការដោះស្រាយវិវាទ

វិវាទណាមួយដែលកើតឡើងទាក់ទងនឹងកិច្ចសន្យានេះត្រូវដាក់ជូនទៅក្រុមប្រឹក្សាឃុំ ដើម្បីពិនិត្យ និងសម្រេច។

កិច្ចសន្យានេះ ត្រូវធ្វើឡើងចំនួន០៣ច្បាប់ ហើយត្រូវរក្សាទុកនៅភាគីទាំងពីរ និងបញ្ជូនទៅរតនាគារខេត្តមួយច្បាប់។

ដើម្បីជាសក្ខីភាពទៅលើកិច្ចសន្យាបម្រើការងារនេះ ភាគីទាំងពីរបានចុះហត្ថលេខាដូចខាងក្រោម៖

| | |
|---|---|
| **ភាគី «ក»**<br>**មេឃុំ** | **ភាគី «ខ»** |

**ឧទាហរណ៍ទម្រង់កិច្ចសន្យាផ្តល់សេវា**

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត ៖ *រតនគិរី*

ស្រុក ៖ *អូរជុំ*

ឃុំ ៖ *ចាអ៊ុង*

## កិច្ចសន្យាផ្តល់សេវាកិច្ចការពារកុមារ

កិច្ចសន្យានេះធ្វើឡើងនៅថ្ងៃទី*០១* ខែ*មករា* ឆ្នាំ*២០១៨* រវាងឃុំ*ចាអ៊ុង* ស្រុក*អូរជុំ* ខេត្ត*រតនគិរី* ហៅកាត់ថា ភាគី"ក" និងលោកលោកស្រី *ក* អាយុ ២៥ឆ្នាំ ដែលមានអាសយដ្ឋាននៅភូមិ*ចាអ៊ុងកេត* ឃុំ*ចាអ៊ុង* ស្រុក*អូរជុំ* ខេត្ត*រតនគិរី* សម្រាប់ផ្តល់សេវាគាំទ្រដល់កុមារងាយរងគ្រោះ និងរងគ្រោះដោយអំពើហិង្សាហៅកាត់ថា ភាគី «ខ»។

**ភាគីទាំងពីរព្រមព្រៀងគ្នាដូចតទៅ៖**

**១. លក្ខខណ្ឌការងារ**

**ក. ភាគី «ខ» នឹងបំពេញការងារជូនដល់ឃុំដូចខាងក្រោម៖**

- ប្រមូលទិន្នន័យអំពីកុមារដែលងាយរងគ្រោះ ឬកុមាររងគ្រោះដោយអំពើហិង្សា ឬការរំលោភបំពាន ការជួញដូរទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ។ល។
- រាយការណ៍និងបញ្ជូនកុមាររងគ្រោះទៅកាន់សេវាតាមតម្រូវការ និងការយល់ព្រមរបស់កុមារ
- ធ្វើការប៉ាន់ប្រមាណពីតម្រូវការ ធ្វើការបញ្ជូនកុមារទៅកាន់សេវាពិនិត្យតាមដាន ការទទួលបានសេវាសម្រាប់កុមាររងគ្រោះដោយអំពើហិង្សាឬការរំលោភបំពាន និងកុមារដែលបានបង្រួបបង្រួមជាមួយគ្រួសារបន្ទាប់ពីចាកចេញពីមណ្ឌលកុមារកំព្រា
- អប់រំ ផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងអំពីបញ្ហាកិច្ចការពារកុមារ ការចិញ្ចឹមកូនបែបវិជ្ជមាន សិទ្ធិរបស់កុមារដែលមានទំនាស់ជាមួយច្បាប់ ។ល។
- ចូលរួម និងគាំទ្រការអនុវត្តកម្មវិធីបង្វែរសម្រាប់កុមារដែលមានទំនាស់នឹងច្បាប់
- ចូលរួម និងគាំទ្រយុទ្ធនាការទប់ស្កាត់អំពើហិង្សាលើកុមារ និងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់
- សហការជាមួយអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ អនុវត្តគម្រោងការពារកុមារនៅក្នុងឃុំ និងរាយការណ៍ពីបញ្ហាប្រឈមនានា ដើម្បីលើកក្នុងកិច្ចប្រជុំ គ.ក.ន.ក។

**ខ. ភាគី «ខ» នឹងធ្វើការងារក្រោមការគ្រប់គ្រងផ្ទាល់របស់មេឃុំ ។**

**គ. ភាគី «ខ» នឹងបម្រើការងារនៅក្នុង ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគិរី។**

## ២. រយៈពេលនៃកិច្ចសន្យា

កិច្ចសន្យានេះធ្វើឡើងសម្រាប់រយៈពេល១២ខែ ចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ។

## ៣. ប្រាក់ឧបត្ថម្ភ

ភាគី «ក» នឹងបើកជូនភាគី «ខ» នូវទឹកប្រាក់ឧបត្ថម្ភចំនួន ៥០០.០០០ រៀល (ហាសិបម៉ឺនរៀលគត់) ក្នុងមួយខែ។ ការទូទាត់ប្រាក់នឹងធ្វើឡើងនៅដំណាច់ខែនីមួយៗ បន្ទាប់ពីភាគី«ខ» ដាក់ជូនរបាយការណ៍ប្រចាំខែស្តីពីការលទ្ធផលការងារជូនរដ្ឋបាលឃុំ ។

## ៤. ម៉ោងការងារ

ភាគី«ខ» នឹងបំពេញការងារចំនួន៨ម៉ោងក្នុង១ថ្ងៃ និង៥ថ្ងៃក្នុងមួយសប្តាហ៍ ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ។ ម៉ោងការងារគឺចាប់ពីម៉ោង០៧:០០ ដល់ម៉ោង១១:៣០ ពេលព្រឹក និងឬ ចាប់ពីម៉ោង១៤:០០ ដល់ម៉ោង១៧:៣០ នៅពេលរសៀល។

## ៥. ការឈប់សម្រាកបុណ្យជាតិ និងការឈប់សម្រាកពិសេស

- ភាគី "ខ" មានសិទ្ធិឈប់សម្រាកតាមប្រតិទិនឈប់សម្រាកប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា។
- ភាគី "ខ" មានសិទ្ធិឈប់សម្រាកពិសេសក្នុងឱកាសមានព្រឹត្តិការណ៍ដែលប៉ះពាល់ផ្ទាល់ដល់គ្រួសារនៃបុគ្គលិកនោះ។
- ចំពោះភាគី "ខ" ជាស្ត្រី មានសិទ្ធិឈប់សម្រាកលំហែមាតុភាពរយៈពេល០៣ខែ ដោយទទួលបាននូវប្រាក់ឧបត្ថម្ភប្រចាំខែ។

## ៦. ការបញ្ចប់កិច្ចសន្យា

- ភាគីណាមួយក៏អាចបញ្ចប់កិច្ចសន្យានេះនៅពេលណាក៏បានដោយគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតចំនួន៣០ថ្ងៃជាមុន។
- ក្នុងករណីត្រូវបានបណ្តេញចេញពីការងារ ដោយសារការប្រព្រឹត្តកំហុសធ្ងន់ធ្ងរ កិច្ចសន្យាត្រូវបញ្ចប់ដោយចូលជាធរមានភ្លាម។

## ៧. ការដោះស្រាយវិវាទ

- វិវាទណាមួយដែលកើតឡើងទាក់ទងនឹងកិច្ចសន្យានេះត្រូវដាក់ជូនទៅក្រុមប្រឹក្សាឃុំដើម្បីពិនិត្យ និងសម្រេច។
- កិច្ចសន្យានេះ ត្រូវធ្វើឡើងចំនួន០៣ច្បាប់ ហើយត្រូវរក្សាទុកនៅភាគីទាំងពីរ និងបញ្ជូនទៅរតនាគារខេត្តមួយច្បាប់។
- ដើម្បីជាសក្ខីភាពទៅលើកិច្ចសន្យាបម្រើការងារនេះ ភាគីទាំងពីរបានចុះហត្ថលេខាដូចខាងក្រោម៖

| | |
|---|---|
| **ភាគី «ក»**<br>**មេឃុំ** | **ភាគី «ខ»** |

### ៣.១.៣. ការរៀបចំសំណើសុំថវិកា

- អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ត្រូវធ្វើសំណើថវិកាសម្រាប់អនុវត្តសកម្មភាពសេវាសង្គមរបស់ខ្លួន ឬភ្ជាប់សំណើសុំរបស់សាមីខ្លួន អាណាព្យាបាល ឬតំណាងជនរងគ្រោះ
- បន្ទាប់ពីទទួលបានសំណើសុំថវិកា ស្មៀនឃុំ សង្កាត់ត្រូវធ្វើសំណើសុំគោលការណ៍ចំណាយទៅអាណាប័ក ឬអ្នកទទួលបានការផ្ទេរសិទ្ធិពីអាណាប័ក
- ក្រោយពីទទួលបានគោលការណ៍ចំណាយ ស្មៀនឃុំ សង្កាត់ត្រូវបើកប្រាក់ជូនអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ដោយចុះហត្ថលេខាបញ្ជាក់លើសក្ខីប័ត្រអំពីចំនួនទឹកប្រាក់ដែលបានទទួល
- អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ត្រូវផ្តល់ប្រាក់ជូនសាមីខ្លួន ឬត្រូវប្រជុំជាមួយភាគីពាក់ព័ន្ធ ដើម្បីអនុវត្តសកម្មភាពសេវាសង្គមស្របតាមគោលការណ៍ និងនីតិវិធី។

### ៣.១.៤. ការទូទាត់ថវិកា

- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងភាគីពាក់ព័ន្ធក្នុងការអនុវត្តសកម្មភាពសេវាសង្គម ត្រូវរៀបចំឯកសារយោងចំណាយផ្សេងៗសម្រាប់ការទូទាត់
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវរក្សាទុកឯកសារយោងចំណាយផ្សេងៗសម្រាប់ការទូទាត់ពាក់ព័ន្ធនឹងសកម្មភាពសេវាសង្គមដែលបានអនុវត្តរួចឱ្យបានត្រឹមត្រូវនិងប្រគល់ឱ្យស្មៀនឃុំ សង្កាត់។

## ៣.២. ការតាមដានត្រួតពិនិត្យសកម្មភាពសេវាសង្គម

ការតាមដានត្រួតពិនិត្យ គឺជាកិច្ចការមួយយ៉ាងសំខាន់សម្រាប់ឃុំ សង្កាត់នៅក្នុងការត្រួតពិនិត្យរាល់ដំណើរការនៃការអនុវត្តសកម្មភាពសេវាសង្គមដើម្បីធានាឱ្យមានការឆ្លើយតបនិងដោះស្រាយតម្រូវការប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព និងសមធម៌។ សកម្មភាពនេះត្រូវមានការចូលរួមពីភាគីពាក់ព័ន្ធដូចខាងក្រោម៖

- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងឬមន្ត្រីបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់ ចុះត្រួតពិនិត្យ និងសម្ភាសជាមួយអ្នកទទួលផលពីសកម្មភាពសេវាសង្គម
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងឬមន្ត្រីបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់ រៀបចំរបាយការណ៍ស្តីពីការត្រួតពិនិត្យ ជូនដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងភាគីពាក់ព័ន្ធដទៃទៀត
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងឬមន្ត្រីបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់ ដោយមានការចូលរួមសហការពីការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ស្រុក ក្រុងចុះវាយតម្លៃសកម្មភាពសេវាសង្គមប្រចាំឆ្នាំ និងរៀបចំរបាយការណ៍
- ប្រធាន គ.ក.ន.ក ដឹកនាំកិច្ចប្រជុំប្រចាំខែ និងត្រីមាស ដើម្បីពិភាក្សាអំពីការរីកចម្រើន បញ្ហាប្រឈម និងស្វែងរកដំណោះស្រាយទាក់ទងនឹងការងារអនុវត្តសកម្មភាពសេវាសង្គម។

## ៣.៣. ការតាមដានត្រួតពិនិត្យថវិកាសេវាសង្គម

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ ត្រូវតាមដានត្រួតពិនិត្យការចំណាយថវិកានៅក្នុងការអនុវត្តសកម្មភាពសេវាសង្គម ដោយធ្វើការកត់ត្រារាល់ចំណាយប្រចាំត្រីមាស ដូចឧទាហរណ៍ក្នុងទម្រង់១១ខាងក្រោម៖

## ទម្រង់១១៖

**តារាងតាមដានការចំណាយថវិកាសកម្មភាពសេវាសង្គម**
**ប្រចាំត្រីមាសទី១ ឆ្នាំ២០១៧**

ឃុំ*ចាអ៊ុង* ស្រុក*អូរជុំ* ខេត្ត*រតនគិរី*

| ល.រ | សកម្មភាព/ មុខចំណាយ | ថវិកាគ្រោងក្នុងត្រីមាស | ការចំណាយ | | | នៅសល់ ៥=១-៤ |
|---|---|---|---|---|---|---|
| | | | កន្លងមក | ត្រីមាសនេះ | បូកយោងសរុប ៤=២+៣ | |
| ១ | ផ្តល់ប្រាក់ឧបត្ថម្ភ ឬថ្លៃធ្វើដំណើរសម្រាប់ស្ត្រីមានផ្ទៃពោះដែលងាយរងគ្រោះទៅប្រើប្រាស់សេវាពិនិត្យផ្ទៃពោះ និងសម្រាលកូននៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក | ៨០.០០០ | ០ | ៨០.០០០ | ៨០.០០០ | ០ |
| ២ | ផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារដែលងាយរងគ្រោះបំផុត( ជួសជុលអណ្តូងទឹក ភ្ជាប់បណ្តាញទឹកស្អាតសម្រាប់គ្រួសារក្រីក្រ ) | ១២០.០០០ | ០ | ១១៥.០០០ | ១១៥.០០០ | ៥.០០០ |
| ៣ | ផ្សព្វផ្សាយ និងអប់រំមាតាបិតា ធ្វើចលនាសហគមន៍ និងសកម្មភាពសេវាមូលដ្ឋានស្តីពីសារៈសំខាន់ នៃការប្រើប្រាស់បង្គន់អនាម័យ | ១៧២.០០០ | ០ | ១២៥.០០០ | ១២៥.០០០ | ៤៧.០០០ |
| ៤ | ការផ្តល់កិច្ចសន្យាគ្រូមត្តេយ្យសហគមន៍ | ៣.០០០.០០០ | ០ | ៣.០០០.០០០ | ៣.០០០.០០០ | ០ |
| ៥ | ផ្គត់ផ្គង់សម្ភាររៀន និងបង្រៀន សម្ភារទឹកស្អាត និងអនាម័យដល់មត្តេយ្យសិក្សាសហគមន៍ | ២០០.០០០ | ០ | ១៨៧.០០០ | ១៨៧.០០០ | ១៣.០០០ |
| ៦ | ផ្តល់ការគាំទ្រដល់គ្រួសារដែលមានកុមារបានមករួមរស់ជាមួយគ្រួសារវិញ | ៨៤០.០០០ | ០ | ៨៤០.០០០ | ៨៤០.០០០ | ០ |
| ៧ | ការតាមដានការអនុវត្តសកម្មភាព សេវាសង្គម | ៤៨.០០០ | ០ | ៤៨.០០០ | ៤៨.០០០ | ០ |

| ល.រ | សកម្មភាព/ មុខចំណាយ | ថវិកាគ្រោង ក្នុងត្រីមាស | ការចំណាយ | | | នៅសល់ ៥=១-៤ |
|---|---|---|---|---|---|---|
| | | | កន្លងមក | ត្រីមាសនេះ | បូកយោងសរុប ៤=២+៣ | |
| ៨ | កិច្ចដំណើរការ និងការប្រជុំរបស់ គ.ក.ន.ក | ២៤០.០០០ | ០ | ២២៩.០០០ | ២២៩.០០០ | ១១.០០០ |
| **សរុប** | | **៤.៧០០.០០០** | **០** | **៤.៦២៤.០០០** | **៤៦២.៤០០០** | **៧១.០០០** |

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........
មេឃុំ

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........
អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ

# ជំពូកទី៤

## របាយការណ៍លទ្ធផល នៃការអនុវត្តសកម្មភាព និង ថវិកាសេវាសង្គម

ជំពូកនេះបរិយាយអំពីការរៀបចំរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្ត សកម្មភាព និងថវិកាសេវាសង្គម។



កុមារមត្តេយ្យសហគមន៍អនុវត្តអនាម័យដោយលាងសម្អាតដៃនឹងសាប៊ូ
ភូមិកាឡៃពី ឃុំកាឡៃ ស្រុកអូរជុំ ខេត្តរតនគីរី
© UNICEF Cambodia /2017/Antoine Raab

- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវសហការជាមួយមន្ត្រីបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់ និងភាគីពាក់ព័ន្ធ ដើម្បីរៀបចំរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តសកម្មភាពសេវាសង្គមប្រចាំខែ និងប្រចាំឆ្នាំ(ទម្រង់១២)
- ស្មៀនឃុំ សង្កាត់ ត្រូវសហការជាមួយអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីរៀបចំរបាយការណ៍លទ្ធផលនៃការអនុវត្តថវិកាសេវាសង្គមប្រចាំខែ និងប្រចាំឆ្នាំ(ទម្រង់១៣)
- របាយការណ៍ទាំងពីរខាងលើនេះ ត្រូវដាក់ជូនកិច្ចប្រជុំ គ.ក.ន.ក ពិនិត្យ និងអនុម័ត។ មេឃុំ ចៅសង្កាត់ និងជាប្រធាន គ.ក.ន.ក ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចប្រជុំប្រចាំខែ។



## ទម្រង់១២៖

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត.................................

ក្រុង ស្រុក ខណ្ឌ...........................

ឃុំ សង្កាត់...................................

### របាយការណ៍បូកសរុបលទ្ធផលសកម្មភាពសេវាសង្គមប្រចាំ..............

| ល.រ | សកម្មភាព | លទ្ធផល | | | ចំនួនអ្នកទទួលផល | | បញ្ហា | ដំណោះស្រាយ ឬ អនុសាសន៍ |
|---|---|---|---|---|---|---|---|---|
| | | ឯកតា | គ្រោង | សម្រេចបាន | សរុប | ស្រី | | |
| ១ | ផ្តល់ប្រាក់ឧបត្ថម្ភឬថ្លៃធ្វើដំណើរសម្រាប់ ស្ត្រីមានផ្ទៃពោះដែលងាយរងគ្រោះ ទៅប្រើប្រាស់សេវាពិនិត្យផ្ទៃពោះ និងសម្រាលកូននៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យបង្អែក | នាក់ | | | | | | |
| ២ | ផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារដែលងាយរងគ្រោះបំផុត (ជួសជុលអណ្តូងទឹក និងភ្ជាប់បណ្តាញទឹកស្អាតសម្រាប់គ្រួសារក្រីក្រ) | គ្រួសារ | | | | | | |
| ៣ | ផ្សព្វផ្សាយនិងអប់រំមាតាបិតា ធ្វើចលនាសហគមន៍ និងសកម្មភាពសេវាមូលដ្ឋានស្តីពីសារៈសំខាន់ នៃការប្រើប្រាស់បង្គន់អនាម័យ | វគ្គ | | | | | | |

| ល.រ | សកម្មភាព | លទ្ធផល | | | ចំនួនអ្នកទទួលផល | | បញ្ហា | ដំណោះស្រាយ ឬ អនុសាសន៍ |
|---|---|---|---|---|---|---|---|---|
| | | ឯកតា | គ្រោង | សម្រេចបាន | សរុប | ស្រី | | |
| ៤ | ផ្តល់កិច្ចសន្យាគ្រូមត្តេយ្យសហគមន៍ | នាក់ | | | | | | |
| ៥ | ផ្គត់ផ្គង់សម្ភាររៀន និងបង្រៀន សម្ភារទឹកស្អាត និងអនាម័យ ដល់មត្តេយ្យសហគមន៍ | សាលា | | | | | | |
| ៦ | ផ្តល់ការគាំទ្រដល់គ្រួសារ ដែលមានកុមារបានមករួមរស់ជាមួយគ្រួសារវិញ | គ្រួសារ | | | | | | |
| ៧ | តាមដានសកម្មភាពសេវាសង្គម | ខែ | | | | | | |
| ៨ | កិច្ចដំណើរការ និងការប្រជុំរបស់ ក.គ.ន.ក | ប្រជុំ | | | | | | |

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........
មេឃុំ ចៅសង្កាត់

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........
អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

## ទម្រង់១៣៖

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត..............................

ក្រុង ស្រុក ខណ្ឌ.......................

ឃុំ សង្កាត់..................................

### របាយការណ៍ថវិកាសេវាសង្គមប្រចាំឆ្នាំ...........

| ល.រ | សកម្មភាព និងលទ្ធផល | ថវិកាគ្រោងរៀល (គិតជា រៀល) | ការចំណាយសរុបរៀល | សមតុល្យ |
|---|---|---|---|---|
| ១ | ផ្តល់ប្រាក់ឧបត្ថម្ភ ឬ ថ្លៃធ្វើដំណើរសម្រាប់ស្ត្រីមានផ្ទៃពោះដែលងាយរងគ្រោះ ទៅប្រើប្រាស់សេវាពិនិត្យផ្ទៃពោះ និងសម្រាលកូននៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក | ២០០.០០០ | ១៩៨.០០០ | ២.០០០ |
| ២ | ផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារដែលងាយរងគ្រោះបំផុត (ជួសជុលអណ្តូងទឹក ភ្ជាប់បណ្តាញទឹកស្អាតសម្រាប់គ្រួសារក្រីក្រ) | ៤៤០.០០០ | ៤៣៧.០០០ | ៣.០០០ |
| ៣ | ផ្សព្វផ្សាយអប់រំមាតាបិតា ធ្វើចលនាសហគមន៍ និងសកម្មភាពសេវាមូលដ្ឋានស្តីពីសារៈសំខាន់នៃការប្រើប្រាស់បង្គន់អនាម័យ | ៥៥២.០០០ | ៥៣០.០០០ | ២២.០០០ |
| ៤ | ផ្តល់កិច្ចសន្យាគ្រូមត្តេយ្យសហគមន៍ | ១២.០០០.០០០ | ១២.០០០.០០០ | ០ |
| ៥ | ផ្គត់ផ្គង់សម្ភាររៀន និងបង្រៀន សម្ភារទឹកស្អាត និងអនាម័យដល់មត្តេយ្យសិក្សាសហគមន៍ | ២០០.០០០ | ១៩៦.០០០ | ៤.០០០ |
| ៦ | ផ្តល់ការគាំទ្រដល់គ្រួសារដែលមានកុមារបានមករួមរស់ជាមួយគ្រួសារវិញ | ៣.៣៦០.០០០ | ៣.៣៦០.០០០ | ០ |
| ៧ | តាមដានការអនុវត្តសកម្មភាពសេវាសង្គម | ១៩២.០០០ | ១៨០.០០០ | ១២.០០០ |
| ៨ | កិច្ចដំណើរការ និងការប្រជុំរបស់ គ.ក.ន.ក | ៨៤០.០០០ | ៨២០.៥០០ | ១៩.៥០០ |
| **សរុប** | | **១៧.៧៨៤.០០០** | **១៧.៧២១.៥០០** | **៦២.៥០០** |

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........

មេឃុំ ចៅសង្កាត់

ថ្ងៃ....... ខែ....... ឆ្នាំ........ ........ស័ក ព.ស.២៥.....
ថ្ងៃទី....... ខែ....... ឆ្នាំ........

ស្មៀនឃុំ សង្កាត់



ម្តាយពរទារកមានសំបុត្រកំណើត
ភូមិចាអ៊ុងចាន់ ឃុំចាអ៊ុង  ស្រុកអូរជុំ ខេត្តរតនគីរី
© UNICEF Cambodia /2017/Antoine Raab

# ជំពូកទី៥



# យន្តការគាំទ្រក្នុងការអនុវត្ត សកម្មភាពសេវាសង្គម

ជំពូកនេះបរិយាយអំពីតួនាទីភារកិច្ចរបស់អ្នកពាក់ព័ន្ធក្នុងការគាំទ្រដល់ដំណើរការ
នៃការរៀបចំ និងការអនុវត្តស កម្មភាពសេវាសង្គមឃុំ សង្កាត់។

ការគាំទ្រ និងសម្របសម្រួលរបស់ភាគីពាក់ព័ន្ធនានានៅក្នុងដំណើរការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់ជាយន្តការដ៏សំខាន់ក្នុងការជំរុញឱ្យកាន់តែមានភាពសកម្មរលូន និងប្រសិទ្ធភាព។ ការអនុវត្តសកម្មភាពសេវាសង្គម ពិតមែនតែជាការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុន្តែទាមទារនូវការគាំទ្រ និងសម្របសម្រួលបន្ថែមទៀតពីភាគីពាក់ព័ន្ធ ដូចខាងក្រោម៖

## ៥.១. រដ្ឋបាលរាជធានី ខេត្ត

☞ ដាក់បញ្ចូលបញ្ហា និងតម្រូវការនានារបស់ស្ត្រី យុវជន កុមារ និងជនងាយរងគ្រោះ ដែលស្នើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់(តាមរយៈក្រុង ស្រុក ខណ្ឌ) ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

☞ ជួយសម្របសម្រួលជាមួយមន្ទីរ អង្គភាព ការិយាល័យជំនាញ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដើម្បីស្វែងរកការគាំទ្រផ្នែកបច្ចេកទេស និងថវិកាដល់ឃុំ សង្កាត់ ក្នុងការអភិវឌ្ឍផ្នែកសេវាសង្គម។

☞ ជំរុញទីចាត់ការផែនការ និងវិនិយោគ អង្គភាព និងទីចាត់ការពាក់ព័ន្ធ ក្នុងការ៖

- ផ្សព្វផ្សាយ និងអភិវឌ្ឍន៍សមត្ថភាពដើម្បីបង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងភាគីពាក់ព័ន្ធនានា
- ជំរុញ និងគាំទ្រដល់ឃុំ សង្កាត់ ក្នុងការផ្សព្វផ្សាយព័ត៌មាន និងការអនុវត្តផ្នែកសង្គម នៅក្នុងឃុំ សង្កាត់របស់ខ្លួន
- សម្របសម្រួលជាមួយមន្ទីរ អង្គភាពជំនាញ អង្គការសង្គមស៊ីវិលនិងអ្នកពាក់ព័ន្ធក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអភិវឌ្ឍផ្នែកសង្គមនិងបូកសរុបរបាយការណ៍វឌ្ឍនភាពសេវាសង្គមប្រចាំខែ និងរាយការណ៍ជូនអភិបាលរាជធានី ខេត្ត។

☞ ផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត ក្នុងការ ៖

- ស្វែងរកការគាំទ្រពីស្ថាប័ន និងមន្ទីរជំនាញពាក់ព័ន្ធ ដើម្បីចូលរួមដោះស្រាយបញ្ហាស្ត្រី យុវជន កុមារ និងជនងាយរងគ្រោះដែលក្រុមប្រឹក្សាឃុំសង្កាត់មិនអាចដោះស្រាយបាន
- ពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាង គ.ក.ស.ក របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយនិង គ.ក.ន.ក និងអ្នកពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហា ស្ត្រី យុវជន កុមារ និងជនងាយរងគ្រោះនៅថ្នាក់ឃុំ សង្កាត់
- ចូលរួមតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពអភិវឌ្ឍផ្នែកសេវាសង្គម នៅឃុំ សង្កាត់ និងចែករំលែកព័ត៌មានដល់រដ្ឋបាលឃុំ សង្កាត់។

## ៥.២. រដ្ឋបាលក្រុង ស្រុក ខណ្ឌ

☞ ដាក់បញ្ចូលបញ្ហា និងតម្រូវការនានារបស់ស្ត្រី យុវជន និងកុមារ និងជនងាយរងគ្រោះដែលបានស្នើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

☞ ជួយសម្របសម្រួលជាមួយការិយាល័យ និងអង្គភាពជំនាញ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីស្វែងរកការគាំទ្រផ្នែកបច្ចេកទេស និងថវិកាដល់ឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសេវាសង្គម

☞ ជំរុញការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ អង្គភាព និងការិយាល័យពាក់ព័ន្ធ ក្នុងការ៖

- ផ្សព្វផ្សាយ និងអភិវឌ្ឍន៍សមត្ថភាពដើម្បីបង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងភាគីពាក់ព័ន្ធ
- ជំរុញ និងគាំទ្រដល់ឃុំ សង្កាត់ ក្នុងការផ្សព្វផ្សាយព័ត៌មាន និងការអនុវត្តផ្នែកសង្គមនៅក្នុងឃុំ សង្កាត់របស់ខ្លួន
- សម្របសម្រួលជាមួយការិយាល័យជំនាញ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអភិវឌ្ឍផ្នែកសង្គម និងបូកសរុបរបាយការណ៍វឌ្ឍនភាពសេវាសង្គមប្រចាំខែ និងរាយការណ៍ជូនអភិបាលក្រុង ស្រុក ខណ្ឌ។

☞ ផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌក្នុងការ៖

- ស្វែងរកការគាំទ្រពីស្ថាប័ន និងការិយាល័យជំនាញពាក់ព័ន្ធ ដើម្បីចូលរួមដោះស្រាយបញ្ហាស្ត្រី យុវជន កុមារ និងជនងាយរងគ្រោះ ដែលក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចដោះស្រាយបាន
- ពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាង គ.ក.ស.ក របស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ជាមួយនឹង គ.ក.ស.ក របស់ក្រុមប្រឹក្សារាជធានី ខេត្ត និង គ.ក.ន.ក និងអ្នកពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាស្ត្រី យុវជន កុមារ និងជនងាយរងគ្រោះនៅថ្នាក់ឃុំ សង្កាត់
- ចូលរួមតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពអភិវឌ្ឍផ្នែកសេវាសង្គមនៅឃុំ សង្កាត់ និងចែករំលែកព័ត៌មានដល់រដ្ឋបាលឃុំ សង្កាត់។

## ៥.៣. មន្ទីរសុខាភិបាល

☞ ផ្តល់ការគាំទ្រដល់គម្រោងអភិវឌ្ឍន៍ផ្នែកសេវាសង្គម ដែលបានលើកឡើងនៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

- ពង្រឹង និងជំរុញការិយាល័យស្រុកប្រតិបត្តិ និងមណ្ឌលសុខភាពក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ដើម្បីអនុវត្តសកម្មភាពលើកកម្ពស់សុខភាពមាតា និងទារក
- ផ្តល់យោបល់ និងជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងការលើកកម្ពស់សុខភាពមាតា និងទារក
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពលើកកម្ពស់សុខភាពមាតា និងទារក
- គាំទ្រការអនុវត្តសកម្មភាពសេវាសង្គមនានាតាមគោលការណ៍ណែនាំ និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធ។

## ៥.៤. មន្ទីរអប់រំយុវជន និងកីឡា



- ផ្តល់ការគាំទ្រដល់គម្រោងអភិវឌ្ឍន៍ផ្នែកសេវាសង្គម ដែលបានលើកឡើងនៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ពង្រឹង និងជំរុញការិយាល័យអប់រំ យុវជននិងកីឡា ក្រុង ស្រុក ខណ្ឌ និងនាយកសាលាបឋមសិក្សាក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក និងភាគីពាក់ព័ន្ធដើម្បីរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ទាក់ទងនឹងការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍
- តាមដានត្រួតពិនិត្យ និងវាយតម្លៃដំណើការមត្តេយ្យសិក្សាសហគមន៍
- គាំទ្រការអនុវត្តសកម្មភាពសេវាសង្គមនានាតាមគោលការណ៍ណែនាំ និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធ។

## ៥.៥. មន្ទីរអភិវឌ្ឍន៍ជនបទ

- ផ្តល់ការគាំទ្រដល់គម្រោងអភិវឌ្ឍន៍ផ្នែកសេវាសង្គម ដែលបានលើកឡើងនៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ពង្រឹង និងជំរុញការិយាល័យអភិវឌ្ឍន៍ជនបទក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក អនុវត្តសកម្មភាពលើកកម្ពស់អនាម័យនៅមូលដ្ឋាន
- ផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងប្រជាពលរដ្ឋទាក់ទងនឹងការលើកកម្ពស់អនាម័យនៅមូលដ្ឋាន
- ផ្តល់យោបល់ និងជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងការលើកកម្ពស់អនាម័យនៅមូលដ្ឋាន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពលើកកម្ពស់អនាម័យនៅមូលដ្ឋាន

- គាំទ្រការអនុវត្តសកម្មភាពសេវាសង្គមនានាតាមគោលការណ៍ណែនាំនិងឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធ។

## ៥.៦. មន្ទីរកិច្ចការនារី

- ផ្តល់ការគាំទ្រដល់គម្រោងអភិវឌ្ឍន៍ផ្នែកសេវាសង្គម ដែលបានលើកឡើងនៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ពង្រឹង និងជំរុញការិយាល័យកិច្ចការនារីក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ដើម្បីអនុវត្តសកម្មភាពលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី
- ផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងប្រជាពលរដ្ឋទាក់ទងនឹងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី
- ផ្តល់យោបល់ និងជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី
- គាំទ្រការអនុវត្តសកម្មភាពសេវាសង្គមនានាតាមគោលការណ៍ណែនាំ និងឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធ។

## ៥.៧. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- ផ្តល់ការគាំទ្រដល់គម្រោងអភិវឌ្ឍន៍ផ្នែកសេវាសង្គម ដែលបានលើកឡើងនៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ពង្រឹង និងជំរុញការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ដើម្បីអនុវត្តសកម្មភាពកិច្ចការពារកុមារ និងជនងាយរងគ្រោះ
- ផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងប្រជាពលរដ្ឋទាក់ទងនឹងសកម្មភាពកិច្ចការពារកុមារ និងជនងាយរងគ្រោះ
- ផ្តល់យោបល់ និងជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់គ.ក.ន.ក ក្នុងការលើកកម្ពស់កិច្ចការពារកុមារ និងជនងាយរងគ្រោះ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពកិច្ចការពារកុមារ និងជនងាយរងគ្រោះ
- ស្វែងរកការគាំទ្រពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់ខេត្ត ក្នុងការដោះស្រាយបញ្ហានានា ដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ និងជនងាយរងគ្រោះ

- ☞ គាំទ្រការអនុវត្តសកម្មភាពសេវាសង្គមនានាតាមគោលការណ៍ណែនាំ និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធ។

## ៥.៨. អង្គការសង្គមស៊ីវិល

- ☞ ផ្តល់ការគាំទ្រដល់គម្រោងអភិវឌ្ឍន៍ផ្នែកសេវាសង្គម ដែលបានលើកឡើងនៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ☞ ចូលរួមក្នុងការពិភាក្សា ពិគ្រោះយោបល់ និងចែករំលែកព័ត៌មាននានាដែលពាក់ព័ន្ធនឹងដំណើរការរៀបចំ និងការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់
- ☞ ចូលរួមផ្តល់ការអភិវឌ្ឍសមត្ថភាពដល់អ្នកពាក់ព័ន្ធ
- ☞ ចូលរួមគាំទ្រផ្នែកធនធានថវិកា សម្ភារ និងបច្ចេកទេសដល់ឃុំ សង្កាត់។

## ៥.៩. ប្រជាពលរដ្ឋ

- ☞ ចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្តក្នុងកិច្ចប្រជុំពិគ្រោះយោបល់ វគ្គផ្សព្វផ្សាយ ការកំណត់បញ្ហា និងតម្រូវការសេវាសង្គមអាទិភាពនានាក្នុងភូមិ
- ☞ ចូលរួមយ៉ាងសកម្មក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពសេវាសង្គម។

# ឧបសម្ព័ន្ធ

# ការកំណត់មាតិកាថវិកានិងលិខិតយុត្តិការចំណាយសម្រាប់ទូទាត់សេវាសង្គមនៅរដ្ឋបាលឃុំ សង្កាត់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋាន រតនាគារជាតិ
លេខ ៖...[illegible]...អ.រ.ធ.ជ

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ២០១៨

**សេចក្ដីណែនាំ**

**ស្ដីពី**

**ការកំណត់មាតិកាថវិកា និងលិខិតយុត្តិការចំណាយ**
**សម្រាប់ទូទាត់សេវាសង្គមនៅរដ្ឋបាលឃុំ សង្កាត់**

យោងសេចក្ដីណែនាំលេខ ០៥១ សណន.គជអប ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ ស្ដីពីការអនុវត្តមុខងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅរដ្ឋបាលឃុំ សង្កាត់ និង ដើម្បីមានមូលដ្ឋានក្នុងការប្រើប្រាស់មាតិកាថវិកា និងការរៀបចំលិខិតយុត្តិការចំណាយភ្ជាប់តាមអាណត្តិបើកប្រាក់របស់រដ្ឋបាលឃុំ សង្កាត់ អគ្គនាយកដ្ឋានរតនាគារជាតិសូមធ្វើការណែនាំដូចខាងក្រោម÷

១-ថវិកាដែលមានប្រភពពីដៃគូអភិវឌ្ឍន៍ ឆ្លងកាត់ចំណូល ចំណាយថវិការដ្ឋ ត្រូវកត់ត្រានៅរតនាគារថ្នាក់កណ្ដាល ជាចំណូលថវិការដ្ឋ (គណនីលេខ ៧៥០៤១/៧៥០៤២) និងជាចំណាយថវិការដ្ឋឧបត្ថម្ភធនដល់រដ្ឋបាលឃុំ សង្កាត់ (គណនីលេខ ៦៥០១៣)។ រីឯនៅរតនាគាររាជធានី ខេត្ត និងរដ្ឋបាលឃុំ សង្កាត់ ត្រូវកត់ត្រាជាចំណូលថវិកាបានពីឧបត្ថម្ភធនពីថ្នាក់ជាតិ (គណនីលេខ ៧៥០១១/៧៥១១១)។

២-ថវិកាដែលមានប្រភពពីដៃគូអភិវឌ្ឍន៍ មិនឆ្លងកាត់ចំណូល ចំណាយថវិការដ្ឋ ត្រូវកត់ត្រានៅរតនាគាររាជធានី ខេត្ត និងរដ្ឋបាលឃុំ សង្កាត់ ជាចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ (គណនីលេខ ៧៥០៤១/៧៥០៤២) ឬ (គណនីលេខ ៧៥១៤១/៧៥១៤២)។

៣-ការចំណាយថវិកាដើម្បីបម្រើឱ្យសកម្មភាពសេវាសង្គមដូចជា លើកកម្ពស់សុខភាពមាតានិងកុមារ និងអាហារូបត្ថម្ភ បង្កើតនិងដំណើរការមត្តេយ្យសិក្សាសហគមន៍ លើកកម្ពស់ទឹកស្អាតនិងអនាម័យ លើកកម្ពស់សមភាពយេនឌ័រ សកម្មភាពបង្កើនចំណូលគ្រួសារ (ដូចជាបណ្ដុះបណ្ដាលបច្ចេកទេសជាដើម) ការអប់រំឪពុកម្ដាយ ការអប់រំកុមារតូច លើកកម្ពស់ផលពិការ ការថែទាំចាស់ជរា កិច្ចការពារកុមារ (ដូចជាការបង្ការនិងទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងកុមារ ការទប់ស្កាត់ការបំបែកកុមារពីគ្រួសារយកទៅដាក់ក្នុងមណ្ឌលថែទាំកុមារ និងបញ្ហាពាក់ព័ន្ធផ្សេងៗទៀត) ចំណាកស្រុក និងការគាំទ្រការអនុវត្តការងារ



អាគារលេខ ១៩ វិថី ព្រះមហាក្សត្រិយានីកុសុមៈ (ផ្លូវលេខ ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : ០២៣ ៧២២ ៨១៦

អគ្រានុក្ខលដ្ឋាន ។ល។ ត្រូវប្រើគណនី/អនុគណនី និងសក្ខីបត្រដែលបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធដែលមានភ្ជាប់ជាមួយសេចក្តីណែនាំនេះ។

**៤**-ការចំណាយលើសកម្មភាពទាំងអស់ (ដូចចំណុច៣) អាចអនុវត្តនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន ឬនីតិវិធីចំណាយធម្មតា។

**៥**-ការបើកផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រួមគ្គេយ្យសហគមន៍តាមរជ្ជទេយ្យបុរេប្រទាន រដ្ឋបាលឃុំ សង្កាត់ ត្រូវភ្ជាប់ជាមួយអាណត្តិទូទាត់នូវគោលការណ៍ចំណាយ ប័ណ្ណចំណាយសាច់ប្រាក់ និងតារាងប្រាក់ឧបត្ថម្ភ។ ដោយឡែកកិច្ចសន្យា ត្រូវរក្សាទុកនៅរដ្ឋបាលឃុំ សង្កាត់ ។

**៦**-ការបើកផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រួមគ្គេយ្យសហគមន៍មានចំនួនច្រើននាក់តាមរូបភាពទូទាត់ត្រង់ រដ្ឋបាលឃុំ សង្កាត់ ត្រូវភ្ជាប់ជាមួយអាណត្តិបើកប្រាក់នូវតារាងប្រាក់ឧបត្ថម្ភ។ ដោយឡែកកិច្ចសន្យា ត្រូវរក្សាទុកនៅរដ្ឋបាលឃុំ សង្កាត់។ នៅពេលបើកប្រាក់ឧបត្ថម្ភ គ្រួមគ្គេយ្យសហគមន៍ត្រូវចុះហត្ថលេខាទទួលប្រាក់នៅលើតារាងប្រាក់ឧបត្ថម្ភ (ករណីពុំមានគណនីនៅធនាគារ)។ រដ្ឋបាលឃុំ សង្កាត់ ត្រូវភ្ជាប់តារាងប្រាក់ឧបត្ថម្ភដែលមានហត្ថលេខាអ្នកទទួលប្រាក់លើកមុនជាមួយអាណត្តិបើកប្រាក់ និងតារាងប្រាក់ឧបត្ថម្ភសម្រាប់ខែថ្មី។

**៧**-ថវិកាដែលបានពីដៃគូអភិវឌ្ឍន៍នានានៅដំណាច់ឆ្នាំ រដ្ឋបាលឃុំ សង្កាត់ត្រូវបញ្ជូនរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តថវិកាសម្រាប់អភិវឌ្ឍន៍ផ្នែកសង្គមមករតនាគារពាក់ព័ន្ធដើម្បីឱ្យគណនេយ្យករធ្វើការបន្ថយពីទឹកប្រាក់ចំណូលថវិកាក្នុងឆ្នាំដោយកត់ត្រា ខាងឥណពន្ធ គណនីចំណូលថវិកា (លេខ ៧៥...) និងខាងឥណទាន គណនីចំណូលផ្សេងៗ និងបង្វែរវង់ចាំដោះស្រាយ (លេខ ៤៧០៦)។

**៨**-នៅឆ្នាំបន្ទាប់ មេឃុំ ចៅសង្កាត់ត្រូវបញ្ចូលតួលេខដែលបានបន្ថយពីចំណូលនៅឆ្នាំមុនទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ។ ពេលដែលគម្រោងថវិកាត្រូវបានផ្តល់អនុលោមភាព និងប្រគល់មករតនាគារ គណនេយ្យករឃុំ សង្កាត់ត្រូវកត់ត្រា ខាងឥណពន្ធ គណនីចំណូលផ្សេងៗនិងបង្វែរវង់ចាំដោះស្រាយ (លេខ ៤៧០៦) និងខាងឥណទាន គណនីចំណូលថវិកា (លេខ ៧៥...)។

**៩**- សេចក្តីណែនាំលេខ ១៦៤៦ អ.រតន ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ ត្រូវទុកជានិរាករណ៍។

ទទួលបានសេចក្តីណែនាំនេះ សូមលោកប្រធានគ្រប់នាយកដ្ឋាន អធិការកិច្ចរតនាគារ និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានរតនាគារជាតិត្រូវចាត់ចែងអនុវត្តឱ្យទទួលបានលទ្ធផលល្អប្រសើរ។

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ

បណ្ឌិត ខឡូ ប៊ុនឆ្នារុង

**<u>ចម្លងជូន៖</u>**

- អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
  " ដើម្បីសហការអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ទំព័រទី ២

ឧបសម្ព័ន្ធភ្ជាប់សេចក្តីណែនាំលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០១៨

## ការកំណត់មាតិកាថវិកានិងលិខិតយុត្តិការចំណាយភ្ជាប់តាមអាណត្តិបើកប្រាក់ សម្រាប់ទូទាត់ចំណាយថវិកាលើសកម្មភាពសេវាសង្គមរបស់រដ្ឋបាលឃុំ សង្កាត់

ការចំណាយថវិកាលើសកម្មភាពសេវាសង្គមរបស់រដ្ឋបាលឃុំ សង្កាត់ អាចអនុវត្តនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន ឬ នីតិវិធីចំណាយធម្មតា* តាមរយៈការបោះផ្សាយអាណត្តិបើកប្រាក់ភ្ជាប់មកជាមួយនូវដីកាអមបញ្ចេញអាណត្តិបើកប្រា' ដីកាអមលិខិតយុត្តិការ សំណើសុំទូទាត់ចំណាយថវិកា និងលិខិតយុត្តិការមួយចំនួន ផ្អែកតាមប្រភេទនិងសកម្មភាពចំណាយនីមួយៗ ដូចខាងក្រោម ÷

| ល.រ | កម្មវត្ថុចំណាយ | នីតិវិធី និងឯកសារយោង | | មាតិកា ចំណាយថវិកា |
|---|---|---|---|---|
| | | នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន | នីតិវិធីចំណាយធម្មតា | |
| ០១ | ផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូមត្តេយ្យសហគមន៍ ជំនួយការរដ្ឋបាលឃុំសង្កាត់ ជំនួយការការងារសេវាសង្គមរដ្ឋបាលឃុំ សង្កាត់ ភ្នាក់ងារទ្រទ្រង់សុខភាពភូមិ ម្តាយបង្គោលនិងអ្នកពាក់ព័ន្ធផ្សេងទៀតសម្រាប់សកម្មភាពលើកកម្ពស់ចំណេះដឹង ការផ្សព្វផ្សាយ កិច្ចប្រជុំនិង សេវាចុះមូលដ្ឋាន និងចុះយុទ្ធនាការនានាក្នុងសកម្មភាពសេវាសង្គមនៅតាមសហគមន៍ | -គោលការណ៍ចំណាយ (មានការបញ្ជាក់ឯកភាពពីមេឃុំ ចៅសង្កាត់លើសំណើរបស់សាម៉ីជនឬការបញ្ជាក់ឯកភាពរបស់មេឃុំ ចៅសង្កាត់លើសំណើរបស់រជ្ជទេយ្យករបុរេប្រទាន)<br>-ប័ណ្ណចំណាយ<br>-តារាងប្រាក់ឧបត្ថម្ភ (មានការបញ្ជាក់ទទួលស្គាល់ពីមេឃុំ ចៅសង្កាត់)<br>**បញ្ជាក់÷** កិច្ចសន្យារវាងរដ្ឋ-បាលឃុំសង្កាត់និងគ្រូមត្តេយ្យសិក្សាសហគមន៍, ជំនួយការរដ្ឋបាលឃុំ សង្កាត់ ជំនួយការការងារសេវាសង្គមរដ្ឋបាលឃុំ សង្កាត់ ភ្នាក់ងារទ្រទ្រង់សុខភាពភូមិ ម្តាយបង្គោល | -តារាងប្រាក់ឧបត្ថម្ភ (មានការបញ្ជាក់ទទួលស្គាល់ពីមេឃុំ ចៅសង្កាត់)<br>**បញ្ជាក់÷** កិច្ចសន្យារវាងរដ្ឋ-បាលឃុំសង្កាត់និងគ្រូមត្តេយ្យសិក្សាសហគមន៍, ជំនួយការរដ្ឋបាលឃុំសង្កាត់ ជំនួយការការងារសេវាសង្គមរដ្ឋបាលឃុំ សង្កាត់ ភ្នាក់ងារទ្រទ្រង់សុខភាពភូមិ ម្តាយបង្គោលនិងអ្នកពាក់ព័ន្ធផ្សេងទៀតត្រូវរក្សាទុកនៅឃុំ សង្កាត់ | អនុគណនី៦១០៩៣ "បុគ្គលិកសម្ហហភាពសាធារណៈផ្សេងៗ" |

ទំព័រទី ១

| | | | | |
|---|---|---|---|---|
| | | និងអ្នកពាក់ព័ន្ធផ្សេងទៀត ត្រូវរក្សាទុកនៅរដ្ឋបាលឃុំ សង្កាត់ | | |
| ០២ | សោហ៊ុយដឹកជញ្ជូន ឬធ្វើដំណើររបស់ ÷<br>-ជនក្រីក្រ ជនងាយរងគ្រោះ និងជនពិការ<br>-កុមារក្រីក្រ កុមាររងគ្រោះ កុមារងាយរងគ្រោះ** និងកុមារពិការ<br>-គ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះ***។ល។ | -គោលការណ៍ចំណាយ (មានការបញ្ជាក់ឯកភាពពីមេឃុំ ចៅសង្កាត់លើសំណើរបស់សាម៉ីជន ឬ អាណាព្យាបាល ឬ ការបញ្ជាក់ឯកភាពរបស់មេឃុំ ចៅសង្កាត់លើសំណើរបស់រដ្ឋទេយ្យករបុរេប្រទាន)<br>-ប័ណ្ណចំណាយ<br>- វិក្កយបត្រ ឬ សក្ខីប័ត្រចំណាយ<br>-តារាងប្រាក់ឧបត្ថម្ភ (មានការបញ្ជាក់ទទួលស្គាល់ពីមេឃុំ ចៅសង្កាត់) | -សំណើសុំរបស់សាម៉ីជន ឬ អាណាព្យាបាល (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-តារាងប្រាក់ឧបត្ថម្ភ (មានការបញ្ជាក់ទទួលស្គាល់ពីមេឃុំ ចៅសង្កាត់) | អនុគណនី៦១០២១ “ការជួលមធ្យោបាយដឹកជញ្ជូន” |
| ០៣ | ចំណាយជួយជនរងគ្រោះដោយសារគ្រោះមហន្តរាយ ឬឧបទ្ទវហេតុផ្សេងៗ | -គោលការណ៍ចំណាយ (ការបញ្ជាក់ឯកភាពពីមេឃុំ ចៅសង្កាត់លើសំណើរបស់សាម៉ីជន/អាណាព្យាបាល/មន្ត្រីភូមិ/តំណាងជនរងគ្រោះ ឬ ការបញ្ជាក់ឯកភាពរបស់មេឃុំ ចៅសង្កាត់លើសំណើរបស់រដ្ឋទេយ្យករបុរេប្រទាន)<br>-ប័ណ្ណចំណាយ<br>-តារាងប្រាក់ឧបត្ថម្ភ (មានការបញ្ជាក់ទទួលស្គាល់ពីមេឃុំ ចៅសង្កាត់) | -សំណើសុំរបស់សាម៉ីជន/អាណាព្យាបាល/មន្ត្រីភូមិ/តំណាងជនរងគ្រោះ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-តារាងប្រាក់ឧបត្ថម្ភ (មានការបញ្ជាក់ទទួលស្គាល់ពីមេឃុំ ចៅសង្កាត់) | អនុគណនី៦២០២៤ “ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ” |
| ០៤ | ចំណាយលើការទិញ សម្ភារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ | -សំណើសុំរបស់សាលាឃុំ មណ្ឌលសុខភាព មត្តេយ្យ | សំណើសុំរបស់សាលាឃុំ មណ្ឌលសុខភាព មត្តេយ្យ | -អនុគណនី៦០០១១ “សម្ភារផ្គត់ផ្គង់ |

ទំព័រទី ២

| | | | | |
|---|---|---|---|---|
| | ដល់សាលាឃុំ មណ្ឌលសុខភាព មត្តេយ្យសិក្សាសហគមន៍ សាលារៀនដូចជា៖<br>- សម្ភារលាងសម្អាតដៃ សាប៊ូ<br>- សម្ភារភ្ជាប់បណ្តាញទឹក និង សម្ភារសម្រាប់សាងសង់បង្គន់អនាម័យ ដូចជា ចានបង្គន់, កង់លូ<br>- ធុងទឹក ពាងទឹក ធុងចម្រោះ សម្ភារអនាម័យ សម្រាប់កូនក្មេង | សិក្សាសហគមន៍ សាលារៀន (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-គោលការណ៍ចំណាយ (មានការបញ្ជាក់ឯកភាពពីមេឃុំ ចៅសង្កាត់លើសំណើរបស់សាមីជនឬ អាណាព្យាបាល ឬការបញ្ជាក់ឯកភាពរបស់មេឃុំ ចៅសង្កាត់លើសំណើរបស់រដ្ឋទេយ្យករបុរេប្រទាន)<br>-វិក្កយបត្រ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-តារាងរាយនាមអ្នកទទួលសម្ភារ (ក្នុងករណីលើសពី ១នាក់)<br>-ប័ណ្ណចំណាយ | សិក្សាសហគមន៍ សាលារៀន (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-វិក្កយបត្រ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-តារាងរាយនាមអ្នកទទួលសម្ភារ (ក្នុងករណីលើសពី ១នាក់) | សម្អាត និងអនាម័យ" ដូចជា សម្ភារលាងសម្អាតដៃ សាប៊ូ<br>-អនុគណនី៦០០១២ "សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និង សំណង់ផ្សេងៗ" ដូចជា សម្ភារភ្ជាប់បណ្តាញទឹក និង សម្ភារសម្រាប់សាងសង់បង្គន់អនាម័យ ដូចជា ចានបង្គន់, កង់លូ<br>-អនុគណនី៦០០៥៣ "សម្ភារប្រើប្រាស់" ដូចជាធុងទឹក ពាងទឹក ធុងចម្រោះ សម្ភារអនាម័យសម្រាប់កូនក្មេង |
| ០៩ | ចំណាយលើការទិញសម្ភារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងផ្តល់ជម្រក សម្រាប់គ្រួសារក្រីក្រនិងងាយរងគ្រោះ (សម្ភារលាងសម្អាតដៃ សាប៊ូ ធុងទឹក ពាងទឹក ធុង ចម្រោះ សម្ភារ ភ្ជាប់បណ្តាញទឹក និង សម្ភារ សម្រាប់សាងសង់បង្គន់អនាម័យ ដូចជា ចានបង្គន់, កង់លូ សម្ភារអនាម័យសម្រាប់ កូនក្មេង និងសម្ភារ | -គោលការណ៍ចំណាយ (មានការបញ្ជាក់ឯកភាពពីមេឃុំ ចៅសង្កាត់លើសំណើរបស់សាមីជន ឬ មានការបញ្ជាក់ឯកភាពរបស់មេឃុំ ចៅសង្កាត់លើសំណើរបស់រដ្ឋទេយ្យករបុរេប្រទាន)<br>-វិក្កយបត្រ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-តារាងរាយនាមអ្នកទទួលសម្ភារ (ក្នុងករណីលើសពី | -សំណើសុំរបស់សាមីជន (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-វិក្កយបត្រ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-តារាងរាយនាមអ្នកទទួលសម្ភារ (ក្នុងករណីលើសពី ១នាក់) | អនុគណនី៦២០២៨ "ជំនួយសង្គមផ្សេងៗទៀត" |

ទំព័រទី ៣

| | | | | |
|---|---|---|---|---|
| | ពាក់ព័ន្ធផ្សេងៗទៀត ជាដើមៗ) | ១នាក់)<br>-ប័ណ្ណចំណាយ | | |
| ០៦ | ចំណាយសម្រាប់បណ្តុះ-បណ្តាល និងផ្សព្វផ្សាយ និងចំណាយផ្តល់សេវាកម្មផ្សេងៗ សំរាប់បណ្តុះបណ្តាលនិងផ្សព្វផ្សាយស្តីពីសកម្មភាពសេវាសង្គមនៅសហគមន៍ សាលាឃុំ មណ្ឌលសុខភាព មត្តេយ្យសិក្សាសហគមន៍ និងសាលារៀនដូចជា សុខភាពមាតានិងកុមារ អាហារូបត្ថម្ភ សកម្មភាពបង្កើនចំណូលគ្រួសារ ការអប់រំឪពុកម្តាយ កិច្ចការពារកុមារ**** ការអភិវឌ្ឍកុមារតូច***** និងបញ្ហាពាក់ព័ន្ធផ្សេងទៀត | -គោលការណ៍ចំណាយ (មានការបញ្ជាក់ឯកភាព ពីមេឃុំ ទៅសង្កាត់)<br>-ប័ណ្ណចំណាយ<br>-វិក័យប័ត្រ ឬ សក្ខីប័ត្រចំណាយ (មានការបញ្ជាក់ពីមេឃុំ ទៅសង្កាត់)<br>-បញ្ជីវត្តមាន | -វិក្កយបត្រ ឬ សក្ខីប័ត្រ (មានការបញ្ជាក់ពីមេឃុំទៅសង្កាត់)<br>-បញ្ជីវត្តមាន | អនុគណនី៦១០៤១ "សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស" |
| ០៧ | ចំណាយសម្រាប់សិក្ខាសាលា និងកិច្ចប្រជុំនានាស្តីពីសកម្ម-ភាពសេវាសង្គមនៅសហគមន៍ សាលាឃុំ មណ្ឌលសុខភាព មត្តេយ្យសិក្សាសហគមន៍ និងសាលារៀន | -គោលការណ៍ចំណាយ (មានការបញ្ជាក់ឯកភាពពីមេឃុំ ទៅសង្កាត់)<br>-ប័ណ្ណចំណាយ<br>-វិក័យប័ត្រ ឬ សក្ខីប័ត្រចំណាយ (មានការបញ្ជាក់ពីមេឃុំ ទៅសង្កាត់)<br>-បញ្ជីវត្តមាន | -វិក័យប័ត្រ ឬ សក្ខីប័ត្រចំណាយ (មានការបញ្ជាក់ពីមេឃុំ ទៅសង្កាត់)<br>-បញ្ជីវត្តមាន | អនុគណនី៦១១០៣ "ប្រជុំ សិក្ខាសាលា និងសន្និសីទ" |
| ០៨ | សម្ភារការិយាល័យសម្រាប់បម្រើដល់សកម្មភាពសេវាសង្គម | -គោលការណ៍ចំណាយ(មានការបញ្ជាក់ឯកភាពពីមេឃុំ ទៅសង្កាត់លើសំណើរបស់ | -សំណើសុំទិញសម្ភារការិយាល័យ<br>-វិក្កយបត្រ ឬ សក្ខីប័ត្រ | អនុគណនី៦០០២១ "សម្ភារការិយាល័យ" |

ទំព័រទី ៤

| | | | | |
|---|---|---|---|---|
| | | អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ ឬ មានការបញ្ជាក់ឯកភាព របស់មេឃុំ ចៅសង្កាត់លើសំណើ របស់ជំនួយការបុរេប្រទាន)<br>-វិក្កយបត្រ ឬ សក្ខីប័ត្រចំណាយ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-បណ្ណចំណាយ | ចំណាយ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់) | |
| ០៩ | សោហ៊ុយធ្វើដំណើររបស់សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ សមាជិកគ.ក.ន.ក ជំនួយការរដ្ឋបាលឃុំ សង្កាត់ ជំនួយ ការការងារសេវាសង្គម****** ក្រុមទ្រទ្រង់សុខភាពភូមិ និង អ្នកពាក់ព័ន្ធក្នុងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និង ងាយរងគ្រោះ កុមារនិង ស្ត្រីក្រីក្រ និងងាយរងគ្រោះ ជនពិការ ការបង្រួបបង្រួមកុមារជាមួយគ្រួសារនិងការតាមដានកុមារ ការគ្រប់គ្រងករណី ការនាំកុមារនិងស្ត្រីដែលប្រឈមនឹងអំពើហិង្សា និងដែលបានទទួលរងអំពើហិង្សាទៅរកសេវាពាក់ព័ន្ធនឹងអនុវត្តសកម្មភាពនានាដែលមានចែងក្នុងសេចក្តីណែនាំនេះ | -គោលការណ៍ចំណាយ (មានការបញ្ជាក់ឯកភាពរបស់មេឃុំ ចៅសង្កាត់លើសំណើ របស់សាមីជន ឬ លើសំណើរបស់ជំនួយការបុរេប្រទាន)<br>-វិក្កយបត្រ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-បញ្ជីឈ្មោះអ្នកទទួលប្រាក់ (ក្នុងករណីធ្វើដំណើរជាក្រុម)<br>-បណ្ណចំណាយ | -វិក្កយបត្រ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-បញ្ជីឈ្មោះអ្នកទទួលប្រាក់ (ក្នុងករណីធ្វើដំណើរជាក្រុម) | ករណីប្រើប្រាស់មធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន÷<br>-អនុគណនី៦០០១៥ "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>ករណីការជួលមធ្យោបាយដឹកជញ្ជូន÷<br>-អនុគណនី៦១០២១ "ការជួលមធ្យោបាយដឹកជញ្ជូន" |
| ១០ | ចំណាយសម្រាប់សេវាថែទាំ និងជួសជុលឧបករណ៍ និងការ | -គោលការណ៍ចំណាយ (មានការបញ្ជាក់ឯកភាពរបស់មេ | -សំណើសុំរបស់តំណាង (មានការបញ្ជាក់ពីមេឃុំ | -ករណីជួលសេវាខាងក្រៅ÷ |

ទំព័រទី ៩

| | | | | |
|---|---|---|---|---|
| | បំពាក់សម្ភារទឹកស្អាត និងអនាម័យ នៅតាមមណ្ឌលសុខភាព មត្តេយ្យសិក្សាសហគមន៍ សាលាឃុំ និងសាលារៀន (ការបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការ និងស្ត្រី រួមមានការកែ សម្រួលជម្រាលបង្កាន់ដៃជណ្ដើរ និងដៃស្ទួចអណ្ដូង និងកន្លែងទុកដាក់ព្រដាសអនាម័យ ប្រដាប់លាងសម្អាតដៃ និងសាប៊ូ) | ឃុំ ចៅសង្កាត់លើសំណើរបស់គណៈ ឬ លើសំណើរបស់រដ្ឋបាលខេត្ត/ក្រុង/ស្រុក (ព្រមទាំងប្រូតូកូល) -វិក្កយបត្រ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់) -ប័ណ្ណចំណាយ | ចៅសង្កាត់) -វិក្កយបត្រ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់) | អនុគណនី៦១០៩៧ "ការថែទាំនិងជួសជុលសម្ភារ និង ឧបករណ៍បច្ចេកទេស" ឬ អនុគណនី ៦១០៩២ ដូចជា ការបំពាក់សម្ភារទឹកស្អាត និងអនាម័យ។ -ក្នុងករណី រដ្ឋបាលឃុំ សង្កាត់ទិញសម្ភារមកធ្វើការរៀបចំជួសជុល និងថែទាំដោយខ្លួនឯង÷ អនុគណនី ៦០០១៨ "សម្ភារផ្គត់ផ្គង់ថែទាំផ្សេងៗ" |
| ១១ | ការផ្ដល់ឧបករណ៍ និងសម្ភារនានាសម្រាប់ដំណើរការមត្តេយ្យសិក្សា សហគមន៍ (តុ កៅអី ក្ដារខៀន ក្រដាសពណ៌ ប្រដាប់ក្មេងលេង សៀវភៅរឿង ផ្ទាំងរូបភាព ក្ដារខៀន ហ្វឺត ប៊ិក ខ្មៅដៃ ជីស ការបិត ក្រៃ ឧបករណ៍រៀបចំ សួនកុមារ) | -គោលការណ៍ចំណាយ (មានការបញ្ជាក់ឯកភាពរបស់មេឃុំ ចៅសង្កាត់លើសំណើរបស់គណៈសហគមន៍ ឬ លើសំណើ របស់រដ្ឋបាលខេត្ត/ក្រុង/ស្រុក (ព្រមទាំងប្រូតូកូល) -វិក្កយបត្រ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់) -ប័ណ្ណចំណាយ | -សំណើសុំទិញឧបករណ៍ និងសម្ភាររបស់គណៈសហគមន៍ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់) -វិក័យប័ត្រ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់) | អនុគណនី៦២០៣១ "ឧបត្ថម្ភសហគមន៍ និងរក្សាសណ្ដាប់ធ្នាប់សន្តិសុខសង្គម" |
| ១២ | ចំណាយសម្រាប់តបណ្ដាញទឹកស្អាត និងបំពាក់សម្ភារអនាម័យនៅតាមមណ្ឌលសុខភាព មត្តេយ្យសិក្សាសហគមន៍ សាលារៀន និង | -គោលការណ៍ចំណាយ (មានការបញ្ជាក់ឯកភាពរបស់មេឃុំ ចៅសង្កាត់លើសំណើរបស់គណៈ ឬ លើសំណើរបស់រដ្ឋបាលខេត្ត/ក្រុង/ស្រុក (ព្រមទាំងប្រូតូកូល) | +ករណីមិនអនុវត្តកិច្ចលទ្ធកម្មសាធារណៈ÷ -សំណើសុំរបស់គណៈ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់) | អនុគណនី៦១០៩៤ "ការថែទាំបណ្ដាញផ្សេងៗ" |

ទំព័រ ៦

| | | | | |
|---|---|---|---|---|
| | សាលាឃុំ(ការបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការ និងស្ត្រីមានផ្ទៃពោះ÷ការកែសម្រួលជម្រាល បង្កាន់ដៃជណ្តើរ និងដៃស្ទប់អណ្តូង និងកន្លែងទុកដាក់ក្រដាសអនាម័យ ប្រដាប់លាង សម្អាតដៃ និងសាប៊ូ) | -វិក្កយបត្រ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-បញ្ជីចំណាយ | -វិក្កយបត្រ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់) | |
| ១៣ | ជួសជុលបន្ទប់ទឹកមុន និងក្រោយសម្រាល អគារនិងរបងមណ្ឌលសុខភាព សាលារៀនមត្តេយ្យសិក្សា សហគមន៍ និងសាលាឃុំ សង្កាត់ | -គោលការណ៍ចំណាយ (មានការបញ្ជាក់ឯកភាពរបស់មេឃុំ ចៅសង្កាត់លើសំណើរបស់ តំណាង ឬ លើសំណើរបស់រដ្ឋបេឡាករបុរេប្រទាន)<br>-វិក្កយបត្រ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-បញ្ជីចំណាយ | -សំណើសុំរបស់តំណាង (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់)<br>-វិក្កយបត្រ (មានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់) | -ករណីជួសជុលដោយខ្លួនឯង÷ អនុគណនី៦០០១២ "សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ"<br>-ករណីជួលសេវាខាងក្រៅ÷ អនុគណនី៦១០៥២ "ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ" |

*ចំពោះការអនុវត្តនីតិវិធីចំណាយធម្មតា ក្នុងករណីមានមុខសញ្ញាចំណាយដែលតម្រូវឱ្យអនុវត្តកិច្ចលទ្ធកម្មសាធារណៈ គឺត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មសាធារណៈរបស់រដ្ឋបាលឃុំ សង្កាត់ ជាធរមាន។

**កុមារដែលងាយរងគ្រោះសំដៅលើកុមារនៅក្នុងសហគមន៍ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារដោយផ្អែកលើសូចនាករមួយចំនួន។ សូចនាករទាំងនោះរួមមាន÷ កុមារដែលប្រឈមនឹងអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ច កុមារត្រូវគេបោះបង់ចោល និងទទួលរងអំពើហិង្សា កុមារកំព្រា កុមាររស់នៅឬ ស្ថិតនៅក្នុងគ្រួសារដែលមានប័ណ្ណសមធម៌ ឬប័ណ្ណអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (និងជាគ្រួសារក្រីក្រតែ ពុំមានប័ណ្ណសមធម៌) កុមាររស់នៅក្នុងមណ្ឌលកុមារដែលត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងគ្រួសារ និងសហគមន៍ កុមារទំនាស់នឹងច្បាប់ កុមាររងផលប៉ះពាល់ពីមេរោគអេដស៍ឬជំងឺអេដស៍ កុមារដែលមិនមានសំបុត្រកំណើត ឬមិនបានចូលរៀន នៅមត្តេយ្យសហគមន៍ឬមត្តេយ្យរដ្ឋ កុមារបោះបង់ការសិក្សាឬប្រឈមនឹងការបោះបង់ការសិក្សា កុមាររស់នៅឬស្ថិតនៅក្នុងគ្រួសារដែលមានមេគ្រួសារទោលឬ ស្ត្រីឬកុមារ ជាមេ

គ្រួសារ; កុមារពិការនិងរស់នៅជាមួយគ្រួសារដែលមានពិការភាពឬជំងឺរ៉ាំរ៉ៃ ឬមិនមានបង្គន់ប្រើប្រាស់ឬខ្វះអនាម័យក្នុងការរស់នៅ កុមាររស់នៅជាមួយនឹងគ្រួសារដែលប្រឈមនឹងបញ្ហាកង្វះសន្តិសុខស្បៀង កុមារប្រឈមនឹងកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ កុមារដែលធ្វើការងារប្រឈមនឹងគ្រោះថ្នាក់ និងកុមារដែលរស់នៅជាមួយគ្រួសារនៅក្នុងសហគមន៍ដែលងាយរងគ្រោះពីគ្រោះធម្មជាតិ និងគ្រោះដែលបង្កឡើងដោយមនុស្សជាដើម។

*** គ្រួសារក្រីក្រ និងងាយរងគ្រោះសំដៅលើគ្រួសារដែលមានប័ណ្ណសមធម៌ ឬប័ណ្ណអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ឬជាគ្រួសារក្រីក្រតែគ្មានប័ណ្ណសមធម៌ឬជាគ្រួសារដែលមានស្ត្រីជាមេគ្រួសារឬមានមេគ្រួសារទោល ឬមានមេគ្រួសារជាកុមារ គ្រួ ដែលប្រឈមនឹងកង្វះសន្តិសុខស្បៀង គ្រួសារដែលមាន ជនពិការ ឬ/និងអ្នកជំងឺរ៉ាំរ៉ៃ ជាដើម។ល។

****កិច្ចការពារកុមារសំដៅលើការទប់ស្កាត់និងការឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ ការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ និងការធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរ ពលកម្មកុមារ និងការអនុវត្តបែបប្រពៃណីដែលមានគ្រោះថ្នាក់ ដល់កុមារ ដូចជាការរៀបអាពាហ៍ពិពាហ៍កុមារ ។

*****ការអភិវឌ្ឍន៍កុមារតូចសំដៅលើ ការចុះបញ្ជីអត្រានុកូលដ្ឋាន ការទទួលបានសុខភាពនិងអាហារូបត្ថម្ភតាំងពីនៅក្នុងផ្ទៃម្ដាយរហូតដល់អាយុ៦ឆ្នាំ ការចូលរៀនថ្នាក់មត្តេយ្យ ការទទួលបានការថែទាំនិងការពារ ការបណ្ដុះបណ្ដាល ការលូតលាស់ផ្នែករាងកាយ សតិបញ្ញាស្មារតី និងការពារពីអាណាព្យាបាលនិងអ្នកពាក់ព័ន្ធ ការទទួលបានទឹកស្អាត អនាម័យ និងសន្តិសុខស្បៀង និងកិច្ចការពាក់ព័ន្ធ ផ្សេងៗទៀតដែលមានចែងនៅក្នុងគោលនយោបាយជាតិស្ដីពីការគាំពារនិងការអភិវឌ្ឍន៍កុមារតូច និងផែនការសកម្មភាពជាតិ ស្ដីពីការគាំពារនិងការអភិវឌ្ឍន៍កុមារតូចជាដើម។

******ការងារសង្គមកិច្ចសំដៅលើការកំណត់រក និងឆ្លើយតបចំពោះករណីកុមារងាយរងគ្រោះ និងរងគ្រោះដោយអំពើហិង្សា ឬរំលោភបំពាន និងការកេងប្រវ័ញ្ចពលកម្មកុមារ ព្រមទាំងកុមារដែលមានហានិភ័យក្នុងការបែកបាក់ពីគ្រួសារបង្កើតដោយមិនចាំបាច់ តាមរយៈការគ្រប់គ្រងករណី និង ការបញ្ជូនកុមារនិងគ្រួសារទៅរកសេវាដែលសមស្រប ព្រមទាំងបន្តតាមដានស្ថានភាពកុមារនិងគ្រួសារក្រោយពេលទទួលបានសេវាចាំបាច់ដើម្បីធានាអំពីសន្តិសុខនិងសុវត្ថិភាពរបស់ពួកគាត់។

# អត្ថន័យនៃសូចនាករទាំង១៤

| ល.រ | សូចនាករ | អត្ថន័យនៃសូចនាករ |
|---|---|---|
| **បញ្ហាសុខភាពមាតា ទារក និងអាហារូបត្ថម្ភ** | | |
| ០១ | ខ្នងផ្ទះមានស្ត្រីមានផ្ទៃពោះមិនបានទៅពិនិត្យផ្ទៃពោះមុនពេលសម្រាល | ▪ ខ្នងផ្ទះដែលមានស្ត្រីមានផ្ទៃពោះម្នាក់ ឬច្រើននាក់មិនបានទទួលការពិនិត្យថែទាំផ្ទៃពោះដោយឆ្មបជំនាញមុនពេលសម្រាល ឬ<br>▪ ខ្នងផ្ទះ ឬគ្រួសារដែលមានស្ត្រីទើបសម្រាលម្នាក់ ឬច្រើននាក់មិនដែលបានទទួលការពិនិត្យថែទាំផ្ទៃពោះមុនពេលសម្រាលសោះក្នុងអំឡុងពេលមានផ្ទៃពោះចុងក្រោយ។ |
| ០២ | ខ្នងផ្ទះមានស្ត្រីមានផ្ទៃពោះមិនបានសម្រាលកូននៅមូលដ្ឋានសុខាភិបាល | ▪ ខ្នងផ្ទះមានស្ត្រីទើបសម្រាលម្នាក់ ឬច្រើននាក់មិនបានទៅសម្រាលកូននៅមូលដ្ឋានសុខាភិបាល( សាធារណៈ ឬឯកជនស្របច្បាប់ )ពេលសម្រាលកូនចុងក្រោយ |
| ០៣ | ខ្នងផ្ទះមានកុមារអាយុ១២-២៣ខែដែលមិនបានចាក់ថ្នាំបង្ការគ្រប់ | ▪ ខ្នងផ្ទះមានកុមារអាយុ ១២-២៣ខែ ដែលមិនបានទទួលថ្នាំបង្ការគ្រប់ ( ថ្នាំបង្ការជម្ងឺរបេង ១ដូស ថ្នាំបង្ការជម្ងឺរលាកថ្លើមប្រភេទបេ ពេលកើត ១ដូស ថ្នាំបង្ការជម្ងឺគ្រុនស្វិតដៃជើងតាមមាត់ ៣ដូស និងចាក់ ១ដូស ថ្នាំបង្ការជម្ងឺខាន់ស្លាក់-តេតាណូស-ក្អកមាន់-រលាកថ្លើមប្រភេទបេ-រលាកស្រោមខួរ ៣ដូស ថ្នាំបង្ការជម្ងឺរលាកសួត/រលាកស្រោមខួរ ៣ដូស ថ្នាំបង្ការជម្ងឺរលាកខួរក្បាល ១ដូស ថ្នាំបង្ការជម្ងឺកញ្ជ្រឹល-ស្អូច ២ដូស ) ដោយផ្អែកលើ៖<br>១. ប័ណ្ណលឿង (ប័ណ្ណថ្នាំបង្ការ)<br>២. តាមរយៈការសាកសួរ។ |
| ០៤ | ខ្នងផ្ទះមានកុមារស្គមស្គាំងនៅអាយុក្រោម៥ឆ្នាំ | ខ្នងផ្ទះមានកុមារអាយុក្រោម ៥ ឆ្នាំដែល៖<br>១. មានទម្ងន់ទាបធៀបនឹងកម្ពស់ ឬ<br>២. មានវិជ្ឍមាត្រពាក់កណ្តាលដើមដៃតិចជាង ១១.៥ស.ម ឬ<br>៣. មើលទៅទំនងស្គមខ្លាំង។ |
| **បញ្ហាទឹកស្អាត និងអនាម័យ** | | |
| ០៥ | ខ្នងផ្ទះគ្មានបង្គន់អនាម័យប្រើប្រាស់ | ▪ ខ្នងផ្ទះដែលគ្មានបង្គន់អនាម័យប្រើប្រាស់រួមទាំងបង្គន់ស្ងួតចាក់ផេះផងដែរ។ |
| ០៦ | ខ្នងផ្ទះមិនបរិភោគទឹកមានសុវត្ថិភាព | ▪ ខ្នងផ្ទះដែលបរិភោគទឹកដោយមិនប្រើប្រាស់វិធីសាស្ត្រធ្វើទឹកឲ្យមានសុវត្ថិភាព រួមមាន៖ ដាំទឹកឲ្យពុះ ប្រើប្រាស់ធុងចម្រោះទឹក ទឹកពិសាដប/ធុង២០លីត្រ ប្រកទឹកដាក់ដបហាលថ្ងៃ ឬក៏ប្រើថ្នាំក្លរីន។ |
| **បញ្ហាកិច្ចការពារកុមារ** | | |
| ០៧ | ខ្នងផ្ទះដែលមានកុមារធ្លាប់ទទួលរងអំពើហិង្សា | ▪ ខ្នងផ្ទះដែលមានកុមាររងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងការមិនអើពើ ( សូមមើលឧបសម្ព័ន្ធទី៣ )។ |

| ល.រ | សូចនាករ | អត្ថន័យនៃសូចនាករ |
|---|---|---|
| ០៨ | ខ្នងផ្ទះមានកុមារងាយរងគ្រោះចំពោះការបែកចេញពីគ្រួសារ | ខ្នងផ្ទះដែលមានកុមាររស់នៅក្នុងគ្រួសារក្រីក្រ ដែល៖<br>១. មានតែឪពុក ឬម្តាយ<br>២. ឪពុកម្តាយមិនរស់នៅជាមួយ<br>៣. គ្រួសារមានអំពើហិង្សាជាប្រចាំ<br>៤. គ្រួសារប្រើប្រាស់គ្រឿងស្រវឹង លេងល្បែងស៊ីសងនិងការប្រើប្រាស់គ្រឿងញៀន<br>៥. គ្រួសារកំពុងមានជម្ងឺរ៉ាំរ៉ៃ និងមានពិការភាព។ |
| ០៩ | ខ្នងផ្ទះមានកុមារវិលត្រលប់មកពីមណ្ឌលកុមារកំព្រារស់នៅជាមួយ | ▪ ខ្នងផ្ទះដែលបានទទួលកូន ឬកុមារ ពីមណ្ឌលកុមារកំព្រា ឬមណ្ឌលថែទាំកុមារមករស់នៅជាមួយ។ |
| ១០ | ខ្នងផ្ទះមានសមាជិកគ្រួសារដែលគ្មានសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត | ▪ ខ្នងផ្ទះដែលមានសមាជិកម្នាក់ ឬច្រើននាក់ ពុំមានសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត<br>▪ សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតខូចខាត ដូចជា រហែក រលុប មិនអាចប្រើប្រាស់បាន ឬបាត់បង់ (សាម៉ីខ្លួន ឬអាណាព្យាបាលអាចទៅស្នើសុំសេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតពីមន្ត្រីអត្រានុកូលដ្ឋានបាន ដោយមិនចាំបាច់ចុះបញ្ជីម្តងទៀតទេ)។ |
| **បញ្ហាការអប់រំកុមារតូច** | | |
| ១១ | ខ្នងផ្ទះមានកុមារអាយុ៣-៥ឆ្នាំមិនបានទទួលការអប់រំគ្រប់ទម្រង់នៃការអប់រំកុមារតូច | ▪ ខ្នងផ្ទះដែលមានកុមារអាយុ៣-៥ឆ្នាំដែលមិនបានចូលរៀននៅសាលាមត្តេយ្យរដ្ឋ មត្តេយ្យឯកជន មត្តេយ្យសហគមន៍ ឬការអប់រំតាមខ្នងផ្ទះ។ |
| ១២ | ខ្នងផ្ទះមានកុមាររៀននៅបឋមសិក្សា ហើយអាណាព្យាបាលមិនដែលបានជួបជាមួយតំណាងសាលា ឬគ្រូ | ▪ ខ្នងផ្ទះដែលមានកុមារចូលរៀននៅសាលាបឋមសិក្សា(ថ្នាក់ទី១-៦) ប៉ុន្តែមាតាបិតា ឬអាណាព្យាបាលមិនដែលបានជួបពិភាក្សា ឬប្រជុំជាមួយគ្រូ ឬនាយកសាលាអំពីបញ្ហាផ្សេងៗ (ឧទាហរណ៍៖ លទ្ធផលសិក្សារបស់កុមារ ការអភិវឌ្ឍសាលារៀន...)។ |
| **បញ្ហាភាពងាយរងគ្រោះ** | | |
| ១៣ | ខ្នងផ្ទះមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ(ប័ណ្ណក្រីក្រ)មានសុពលភាព | ▪ ខ្នងផ្ទះដែលមានគ្រួសារមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ប័ណ្ណក្រីក្រ)មានសុពលភាព។ |
| ១៤ | ខ្នងផ្ទះមានសមាជិកមានពិការភាព | ▪ ខ្នងផ្ទះដែលមានសមាជិក មានការលំបាកក្នុងការមើល ស្តាប់ បំលាស់ទី ឬលំបាកក្នុងការប្រើប្រាស់ផ្នែកណាមួយនៃរាងកាយ ការចងចាំ ការគិត ការនិយាយស្តី ការមើលថែដោយខ្លួនឯង ។ល។ ដែលបង្កការលំបាកក្នុងការចូលរួម និងធ្វើសកម្មភាពនានាក្នុងសង្គម និងជីវិតប្រចាំថ្ងៃ។ |

# ឯកសារជំនួយស្មារតី ស្តីពីប្រភេទនៃអំពើហិង្សាលើកុមារ

ទម្រង់នៃការប្រើអំពើហិង្សាលើកុមារ មានដូចជា៖ អំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្លូវចិត្ត និងការមិនអើពើ រួមទាំង ការកេងប្រវ័ញ្ចនានា ដែលការបង្កអោយមានគ្រោះថ្នាក់ ឬការរំលោភបំពានដល់កុមារដែលត្រូវបានទទួលស្គាល់ជាសកល។

សម្រាប់ប្រទេសកម្ពុជា ទម្រង់នៃអំពើហិង្សាទៅលើកុមារមាន ៤ប្រភេទ ដោយក្នុងនោះមានដូចជា (១) អំពើហិង្សាផ្លូវកាយ (២) អំពើហិង្សាផ្លូវភេទ (៣) អំពើហិង្សាផ្លូវចិត្ត និង (៤)ការមិនអើពើ។ ប្រភេទផ្សេងទៀតនៃការរំលោភបំពានត្រូវបានគេកំណត់ និងទទួលស្គាល់ដូចជា ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ពលកម្មកុមារ និងការជួញដូរកុមារ គឺជាការស្តែងចេញនូវភាពស្មុគ្រស្មាញ ឬការរួមបញ្ចូលនៃប្រភេទអំពើហិង្សាទាំង៤។ ប្រពៃណីទំនៀមទម្លាប់ខ្លះ និងការអនុវត្តដោយគ្រោះថ្នាក់ខ្លះត្រូវបានគេទទួលស្គាល់កាន់តែច្រើនឡើងៗថាជាការរំលោភបំពាន។ ប្រភេទទាំង៤ នៃអំពើហិង្សាលើកុមារមានដូចខាងក្រោម៖

១. **អំពើហិង្សាផ្លូវកាយ៖** ការបង្កគ្រោះថ្នាក់ដល់រាងកាយកុមារដោយចេតនាពីអ្នកដទៃ[១] ដែលអាចត្រូវបានគេហៅថា ទណ្ឌកម្មលើរូបរាងកាយ (ឧទាហរណ៍៖ ការវាយតប់ អង្រួនឱ្យកុមារភិតភ័យ ការចាប់គ្រវាត់ ការដុត ឬធ្វើឱ្យរលាក ការពន្លង់ទឹក ឬការធ្វើឱ្យថប់ដង្ហើម ការបង្កគ្រោះថ្នាក់ផ្សេងៗទៀត រួមមានការបង្ខំឱ្យកុមារលុតជង្គង់ ឬឈររយៈពេលយូរជាដើម ឬក៏សកម្មភាពហិង្សាដទៃទៀតទៅលើរាងកាយ[២]។

២. **អំពើហិង្សាផ្លូវភេទ៖** ការបង្ខំ ឬល្បួងកុមារឱ្យរួមភេទ ទោះបីជាកុមារនោះមានការយល់ដឹង ឬមិនយល់ដឹងពីអ្វីដែលបានកើតឡើងឬកុមារនោះយល់ព្រមក៏ដោយ។ទង្វើទាំងនេះអាចប៉ះពាល់ដល់រូបរាងកាយដូចជាការបៀតបៀនកេរ្តិ៍ខ្មាស់ និងការរំលោភផ្លូវភេទ។ វាក៏អាចជាសកម្មភាពដែលមិនប៉ះពាល់ដល់រាងកាយរបស់កុមារដូចជា ការឱ្យកុមារមើលរឿងអាសអាភាស ឬផលិតសម្ភារ ឬឧបករណ៍អាសអាភាស ឬមើលសកម្មភាពរួមភេទ ឬលើកទឹកចិត្តឱ្យកុមារមានអាកប្បកិរិយាទាក់ទងនឹងផ្លូវភេទមិនសមរម្យ[៣]។

៣. **អំពើហិង្សាផ្លូវចិត្ត៖** ការធ្វើបាបផ្លូវអារម្មណ៍របស់កុមារដែលនាំឱ្យកុមារមានផលប៉ះពាល់ធ្ងន់ធ្ងរ និងយូរអង្វែងទៅលើការអភិវឌ្ឍផ្លូវអារម្មណ៍របស់កុមារ។ ទង្វើទាំងនេះរួមមានដូចជា ការបង្ហាញប្រាប់កុមារថាពួកគេគ្មានតម្លៃ និងគ្មានអ្នកឱ្យស្រលាញ់ គ្មានសមត្ថភាពគ្រប់គ្រាន់ ឬមានតម្លៃគ្រប់គ្រាន់ដូចដែលបុគ្គលណាម្នាក់ត្រូវការនោះទេ។ វាអាចពាក់ព័ន្ធនឹងអាយុ ឬការរំពឹងទុកមិនសមរម្យកាន់តែកើនឡើងចំពោះកុមារ ឬបណ្តាលឱ្យកុមារមានអារម្មណ៍ភ័យខ្លាច ឬមានគ្រោះថ្នាក់ញឹកញាប់[៤]។

៤. **ការមិនអើពើ៖** ការមិនឆ្លើយតបទៅនឹងតម្រូវការជាមូលដ្ឋានរបស់កុមារទាំងផ្លូវកាយ និងឬផ្លូវចិត្ត ដែលអាចនាំឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ការអភិវឌ្ឍរូបរាងកាយ[៥]។

[១] មាត្រា២១៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា២០០៩
[២] របកគំហើយនៃការសិក្សាស្រាវជ្រាវស្តីពី អំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៣
[៣] របកគំហើយនៃការសិក្សាស្រាវជ្រាវស្តីពី អំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៣
[៤] របកគំហើយនៃការសិក្សាស្រាវជ្រាវស្តីពី អំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៣ ទំព័រទី១៧
[៥] របកគំហើយនៃការសិក្សាស្រាវជ្រាវស្តីពី អំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៣

# ឯកសារជំនួយស្មារតី ស្តីពីការធ្វើឲ្យប្រសើរឡើងនូវការថែទាំកុមារនៅតាមគ្រួសារ និងការធ្វើសមាហរណកម្មកុមារ ពីមណ្ឌលថែទាំកុមារ ទៅកាន់គ្រួសារប្រកបដោយសុវត្ថិភាព សម្រាប់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់(គ.ក.ន.ក)

ឯកសារនេះបញ្ជាក់អំពីតួនាទីរបស់ គ.ក.ន.ក ក្នុងការលើកកម្ពស់ចំណេះដឹង និងសមត្ថភាពដើម្បីកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់ និងការអនុវត្តផែនការសកម្មភាពដើម្បីធ្វើឲ្យប្រសើរឡើងនូវការថែទាំកុមារ។ ការធ្វើសមាហរណកម្មកុមារ វាមានសារៈសំខាន់ដោយសារមានកុមារច្រើនហួសប្រមាណកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ (កុមារចំនួន ១៦.៥៧៩នាក់ កំពុងរស់នៅក្នុងមណ្ឌលចំនួន ៤០៦កន្លែង (មណ្ឌលកុមារកំព្រា) ទូទាំងប្រទេស) និង ៧៧%នៃកុមារទាំងនេះ យ៉ាងហោចណាស់មានឪពុក ឬម្តាយម្នាក់ដែលនៅរស់ដែលមានន័យថាពួកគេមិនគួរយកទៅដាក់ឲ្យរស់នៅក្នុងមណ្ឌលថែទាំនោះទេ ប៉ុន្តែគ្រួសាររបស់ពួកគេគប្បីទទួលបានការគាំទ្រដើម្បីថែទាំកូនរបស់ពួកគាត់។ មានការសិក្សាស្រាវជ្រាវកម្រិតសកលជាច្រើនទស្សវត្សរ៍បានបង្ហាញឱ្យដឹងថា គ្រួសារ និងការថែទាំតាមគ្រួសារ គឺប្រសើរបំផុតសម្រាប់ការអភិវឌ្ឍន៍រាងកាយ អារម្មណ៍ ស្មារតីរបស់កុមារក្នុងការសំរេចនូវសក្តានុពលពេញលេញរបស់ពួកគេ។ «មណ្ឌលកុមារកំព្រា» គួរតែជាជម្រើសចុងក្រោយ និងជាដំណោះស្រាយបណ្តោះអាសន្នប៉ុណ្ណោះ។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់លទ្ធផលនៃការស្រាវជ្រាវនេះ និងជឿថាតួនាទីបឋមក្នុងការការពារ និងថែទាំកុមារ គឺជាតួនាទីរបស់គ្រួសារ និងសហគមន៍[៦]។

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) គប្បីត្រួតពិនិត្យលើស្ថានភាពជារួមរបស់កុមារដែលកំពុងត្រូវបានសមាហរណកម្មពីមណ្ឌលថែទាំកុមារ ជួយកៀរគរធនធាននានាដើម្បីជួយគាំទ្រដល់កុមារ និងគ្រួសារ រាយការណ៍ពីស្ថានភាព និងបញ្ហាប្រឈមនានានៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលធ្វើឡើងជារៀងរាល់ខែ។ ក្នុងនោះផងដែរ គ.ក.ន.ក គួរបង្ហាញដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីផែនការសកម្មភាព ជាពិសេសតួនាទីសំខាន់ៗចំនួន ៣ គឺការបង្ការ ការទប់ស្កាត់ និងការបង្រួបបង្រួមគ្រួសារ និងការធ្វើសមាហរណកម្ម។

[៦] សៀវភៅណែនាំស្តីពីការធ្វើឲ្យប្រសើរឡើងនូវការថែទាំកុមារនៅតាមគ្រួសារ និងការធ្វើសមាហរណកម្មកុមារ ចំនួន៣០% ពីមណ្ឌលថែទាំកុមារ ទៅកាន់គ្រួសារប្រកបដោយសុវត្ថិភាពសម្រាប់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់(គ.ក.ន.ក) ខែមេសា ឆ្នាំ២០១៧

| ការបង្ការ | ការទប់ស្កាត់ | ការធ្វើសមាហរណកម្ម |
|---|---|---|
| គឺការរក្សាកុមារឲ្យនៅជួបជុំជាមួយគ្រួសាររបស់គាត់។ កុមារគ្រប់រូប មានសិទ្ធិដែលមិនអាចកាត់ផ្តាច់បាន ក្នុងការបន្តរស់នៅប្រកបដោយសុវត្ថិភាពជាមួយម្តាយ និង/ឬ ឪពុកបង្កើត ក្នុងករណីដែលអាចធ្វើទៅបាន។<br><br>ទំនាក់ទំនងរវាងឪពុកម្តាយ និងកូន គឺជាទំនាក់ទំនងមួយដ៏វិសេសវិសាល ដែលមិនគប្បីកាត់ផ្តាច់ឡើយ លុះត្រាណាតែមានការគំរាមកំហែងចំពោះសុវត្ថិភាពរបស់កុមារ។<br><br>ការបំបែកកុមារចេញពីគ្រួសារបង្កើតរបស់គេ គួរត្រូវបានពិចារណា លុះត្រាណាតែគ្រប់មធ្យោបាយទាំងអស់ ត្រូវបានប្រឹងប្រែងអស់លទ្ធភាព។<br><br>ក្នុងន័យនេះ យើងអាចលើកជាសំណួរសួរថា តើ គ.ក.ន.ក អាចធ្វើអ្វីបានខ្លះ? | គឺជាដំណើរការបញ្ជូនកុមារ និងគ្រួសារទៅកាន់សេវា ឬការថែទាំសមស្របនានាក្នុងគោលបំណង កម្រិត ចំនួននៃការទុកដាក់កុមារដែលមិនសមស្រប និងចំនួនកុមារដែលចូលទៅរស់នៅក្នុង «មណ្ឌលថែទាំកុមារ»។<br><br>ដូចដែលមានចែងក្នុង ប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ និងផែនការពង្រឹងការថែទាំកុមាររបស់ក្រសួង ស.អ.យ. ក្នុងការកែលម្អការថែទាំកុមារ គេត្រូវការឱ្យមានហត្ថលេខាពី គ.ក.ន.ក មុនពេលដែលកុមារត្រូវបានទុកដាក់ឱ្យស្នាក់នៅក្នុងមណ្ឌល ដូច្នេះ គ.ក.ន.ក ត្រូវពិនិត្យឡើងវិញដោយប្រុងប្រយ័ត្នទៅលើករណីនីមួយៗដែលគេបានស្នើឡើង ដើម្បីធានាថារាល់ជម្រើសនៃការថែទាំជំនួសដទៃទៀតក្រៅពីមណ្ឌលថែទាំកុមារត្រូវបានពិនិត្យអស់លទ្ធភាព។<br><br>តើគ្រួសារបានទទួលកិច្ចគាំទ្រសមស្រប ដែរឬទេ? ប្រសិនបើការផ្តល់កិច្ចគាំទ្រសមស្របជូនគ្រួសារបង្កើតមិនអាចប្រព្រឹត្តទៅបាន តើគេបានស្វែងរកការថែទាំជំនួសជាលក្ខណគ្រួសារធម៌ គ្រួសារសាច់ញាតិ និងជម្រើសដទៃទៀតនៅសហគមន៍ ដែរឬទេ? | គ.ក.ន.ក គប្បីធ្វើការត្រួតពិនិត្យ និងបង្កើតឧបករណ៍វាស់វែង ដើម្បីធានាថាកុមារគ្រប់រូប ដែលបានធ្វើសមាហរណកម្មពីមណ្ឌល ប្រមូលធនធាននានា និង តាមដានទៅលើសេចក្តីត្រូវការរបស់ពួកគេ។<br><br>គ.ក.ន.ក គួរចុះមើលកុមារទាំងនេះ និងរាយការណ៍ទៅការិយាល័យ ស.អ.យ ឬ មន្ទីរ ស.អ.យ អំពីស្ថានភាពរបស់កុមារ ដោយផ្តល់មតិយោបល់អំពីចំណាត់ការជាបន្ទាន់ ដើម្បីគាំទ្រកុមារដែលប្រឈម ក្រោយពេលធ្វើការបង្រួបបង្រួមជាមួយគ្រួសាររបស់ពួកគេ។ កុមារនឹងត្រូវការឱ្យមានកិច្ចគាំទ្រជាសម្ភារៈ និងកិច្ចគាំទ្រក្នុងទម្រង់ជាការផ្តល់មតិយោបល់ដទៃទៀតនៅ ក្នុងដំណើរការសមាហរណកម្មនេះ។ ប្រសិនបើចាំបាច់សូមភ្ជាប់ទំនាក់ទំនងពួកគេជាមួយអ្នកផ្តល់សេវាពាក់ព័ន្ធ។<br><br>គ.ក.ន.ក គួរចែករំលែកព័ត៌មានអំពីកុមារដែលបានធ្វើសមាហរណកម្មរួចជាមួយ គ.ក.ស.ក ស្រុក ដើម្បីគេអាចចែករំលែកព័ត៌មានទាំងនេះក្នុងកិច្ចប្រជុំត្រីមាសជាមួយ និងក្រុមសមាហរណកម្មនៅថ្នាក់ខេត្តក្នុងខេត្តនីមួយៗ និងតាមដានលើសកម្មភាពដែលបានពិភាក្សា និងអនុវត្ត ។ |

គាំទ្រដោយ៖

unicef

ដើម្បីកុមារគ្រប់រូប